សមាគមបុគ្គលិកសិក្សាខ្មែរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កម្មវិធីសិក្សាមើលទីក្រុងជួយ
មានជំនួយពីសហគមន៍អឺរ៉ុប
កម្មវិធីជំនួយផ្នែកសិក្សាធិការនៅកម្ពុជា

# ទស្សនាវដ្ដី លេខ ៣
# គ្រូបង្រៀន



សមាសភាពគណៈកម្មាធិការគណ្ណាយ័ត ស.ប.ស.ខ

ខែមេសា - ឧសភា - មិថុនា ១៩៩៦
ផ្សាយចេញរាល់ត្រីមាស ពិធីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ

## I- គណៈកម្មការតំរង់ទិស - អំណាន និងតាមដាន

1- លោក យ៉ង់ ធី ប្រធាន

2- លោក ស៊ុន ឆ្វនហេង សមាជិក

3- លោក ណាត ប៊ុនរឿន សមាជិក

4- លោក ធ សោ សមាជិក

5- លោក ជា ជាតិ សមាជិក

6- លោក ស៊ុង វ៉ាន់ថន សមាជិក

7- លោកស្រី ហួរ សិរី សមាជិក

8- លោក សង់ មីសែលឡឺប៉ិច សមាជិក

9- លោក សេរា រិទ្ធ សមាជិក

## II- គណៈកម្មការតែងអត្ថបទ

1- លោក យ៉ង់ យ៉ាណូ

2- លោក ឆយ យីហាំង

3- លោក អ៊ុម កុច

4- លោក កង ឱម

5- លោក ពត សុត

6- លោក ផិន សុកហេង

7- អ្នកស្រី ជាន់ សំអោ

8- អ្នកស្រី អ៊ិច សារ៉ូ

9- លោក សំអាន សាយ

10- លោក ប្រាក់ ព្រុំ

11- លោកអធិការបឋមសិក្សានៅគ្រប់ខេត្ត - ក្រុង បណ្តុះបណ្តាលនៅមហាវិទ្យាល័យគរុកោសល្យ

ទស្សនាវដ្តីនេះបោះពុម្ពដោយមានការរួមចំណែកជាបច្ចេកទេស និងហិរញ្ញវត្ថុ
ពី កម្មវិធីទ្រទ្រង់ផ្នែកអប់រំបឋមសិក្សានៅកម្ពុជារបស់សហគមន៍អឺរ៉ុប

Revue publiée avec le concours technique et financier
du Programme d'Appui au Secteur de l'Education Primaire
au Cambodge ( PASEC ) de l'Union Européenne.

# មាតិកាអត្ថបទ

១ - *ពរឆ្នាំថ្មីរបស់ ស.ប.ស.ខ.*

២ - *ពត៌មានរដ្ឋបាល*

- សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

៣ - *វប្បធម៌ទូទៅ - ការអប់រំ*

- ចរិតមនុស្ស និង សីលចរិត
- តំលៃជាតិ
- មជ្ឈដ្ឋាននៃការអប់រំ
- តើអប់រំកុមារដូចម្ដេច ?

៤ - *គរុកោសល្យ - ការគ្រប់គ្រង*

- ហេតុអ្វីបានជាមានការបណ្ដុះបណ្ដាលពីចំងាយនៅកម្ពុជា ?
- សារៈសំខាន់នៃអំនាន
- ការត្រិះរិះពិចារណាពីមេរៀនវិទ្យាសាស្ត្រអនុវត្ត
- គរុកោសល្យនៃសកម្មភាព
- វិន័យសាលារៀន និងការគោរពបុគ្គលិកលក្ខណៈរបស់កុមារ
- ល្បែងល្បងប្រាជ្ញា
- ការរៀបចំសិស្សអោយអង្គុយក្នុងថ្នាក់
- ទព្វន្ត - ការបង្រៀនចំនួន ៧

៥ - *ដំណឹងមរណភាព*



## ក្នុងឱកាសចូលឆ្នាំថ្មីគតអដ្ឋស័ក

## ព.ស.២៥៤០

## គណៈកម្មាធិការកណ្ដាលនៃ

## សមាគមបុគ្គលិកសិក្សាខ្មែរ ( ស.ប.ស.ខ )

សូមប្រសិទ្ធិពរជូនចំពោះសមាជិក សមាជិកានៃសមាគម ព្រម ទាំងបុគ្គលិកសិក្សាទូទាំងប្រទេស សូមប្រកបបានតែសេចក្ដីសុខ សេចក្ដីចំរើន និងសូមទទួលបានជោគជ័យក្នុងការអប់រំ ដើម្បីកសាង សង្គមខ្មែរមានសុខសន្តិភាព និងសំបូររុងរឿងទៅអនាគត ។

សូមឆ្នាំថ្មីនាំមកនូវសុខសិរីសួស្ដី និងជ័យជំនះថ្មី!

# ច្បាប់
## ស្ដីពី
# សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
# នៃព្រះរាជាណាចក្រកម្ពុជា

## ជំពូកទី ៥
## វិន័យ

### មាត្រា ៣៣.

អ្នករាជការរាល់រូប ត្រូវតែគោរពអនុវត្តច្បាប់និងបទបញ្ជា ហើយនឹងការណែនាំថ្នាក់លើរបស់ខ្លួន ។

អ្នករាជការត្រូវទទួលខុសត្រូវចំពោះមុខថ្នាក់លើអំពីកិច្ចការរបស់ខ្លួន និងអំពើដែលអាចធ្វើអោយប៉ះពាល់ទៅលើសេចក្ដីថ្លៃថ្នូរ និងកិត្តិយសរបស់ខ្លួន ។

អ្នករាជការក្នុងក្របខ័ណ្ឌទាំងអស់ ត្រូវតែគោរពបញ្ជាថ្នាក់លើដែលបានចាត់អោយទៅបំរើការងារ ទោះបីទីតំបន់ណាក៏ដោយ ទាំងក្នុងនិងក្រៅប្រទេស ។

### មាត្រា ៣៤.

អ្នករាជការទាំងឡាយមិនអាចឈប់ធ្វើការដោយគ្មានបានទទួលការអនុញ្ញាតជាមុនពីថ្នាក់លើរបស់ខ្លួន រឺដោយគ្មានមូលហេតុត្រឹមត្រូវ ។ ការឈប់ធ្វើការ រឺការខានទៅធ្វើការដោយគ្មានការអនុញ្ញាត រឺដោយគ្មានមូលហេតុត្រឹមត្រូវ អាចបង្កំអោយអ្នករាជការនោះនៅទំនេរគ្មានបៀវត្ស រឺត្រូវផ្អាកបៀវត្ស ។ អ្នករាជការនោះអាចនឹងត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ ។

### មាត្រា ៣៥.

ត្រូវហាមឃាត់ជាដាច់ខាត ដល់អ្នករាជការនូវប្រការខាងក្រោម ៖

១- យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត ។

២- យកឥទ្ធិពលនិងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើ ដើម្បីទាញយកផលប្រយោជន៍អ្វីមួយ

រឺដើម្បីសំឡុត គំរាមកំហែង បំពានសិទ្ធិរបស់ពលរដ្ឋ ។

៣- ប្រកបមុខរបរណាដែលនាំអោយប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃអ្នករាជការ ។

៤- ចូលជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល រឺគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ រឺដោយប្រយោល ។

៥- បោះពុម្ពផ្សាយ រឺធ្វើការផ្សព្វផ្សាយពត៌មានដែលមានពាក់ព័ន្ធនៅក្នុងមុខងារក្រសួង ដោយពុំមានការអនុញ្ញាតជាមុនពីប្រធានស្ថាប័នដែលសាម៉ីខ្លួននៅក្រោមឱវាទ ។

៦- ប្រកបមុខរបរបន្ថែមក្រៅលើមុខងាររបស់ខ្លួនជាអ្នករាជការ ក្នុងករណីដែលលក្ខន្តិកៈដោយឡែកនៃអង្គនីមួយៗហាមឃាត់ ។

អំពើបំពាននិងបទបញ្ញត្តិនៃមាត្រានេះ អាចបណ្តាលអោយទទួលទណ្ឌកម្មផ្នែកវិន័យណាមួយដែលមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ ដោយមិនទាន់គិតដល់ការចោទប្រកាន់ជាបទអាជ្ញាដែលអាចកើតមានឡើងទៀតផង ។

## មាត្រា ៣៦.

អ្នករាជការទាំងឡាយមានសិទ្ធិចូលជាសមាជិក រឺចូលរួមក្នុងការគ្រប់គ្រងសមាគមស្របច្បាប់ ។

## មាត្រា ៣៧.

មន្ត្រី រាជការត្រូវមានអព្យាក្រឹតភាពក្នុងសកម្មភាពការងារ និងហាមឃាត់ដាច់ខាតនូវការប្រើប្រាស់មុខងាររបស់ខ្លួន និងសំភារៈរបស់រដ្ឋដើម្បីបំរើសកម្មភាពនយោបាយដូចខាងក្រោម ៖

១- ធ្វើការដើម្បីផលប្រយោជន៍ដល់បេក្ខជននយោបាយ រឺប្រឆាំងនឹងបេក្ខជននយោបាយណាមួយ ។

២- ធ្វើការដើម្បីផលប្រយោជន៍គណបក្សនយោបាយ រឺប្រឆាំងនឹងគណបក្សនយោបាយណាមួយ ។

ការប្រព្រឹត្តផ្ទុយនឹងមាត្រានេះចាត់ទុកជាកំហុសនិងការធ្វេសធ្វងក្នុងវិជ្ជាជីវៈ ។

## មាត្រា ៣៨.

អ្នករាជការទាំងអស់ត្រូវបង្ហាញអោយឃើញថា ខ្លួនមានសមត្ថភាពក្នុងវិជ្ជាជីវៈជាដរាបក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន ។ អ្នករាជការទាំងអស់ត្រូវទទួលខុសត្រូវពីកំហុស និងការធ្វេសធ្វងក្នុងវិជ្ជាជីវៈព្រមទាំងបទល្មើសដែលខ្លួនបានប្រព្រឹត្តក្នុងមុខងាររបស់ខ្លួន ។

## មាត្រា ៣៩.

កំហុសនិងការធ្វេសធ្វងក្នុងវិជ្ជាជីវៈ ត្រូវយកទណ្ឌកម្មខាងវិន័យទៅអនុវត្ត ។ ការខ្វះខាត រឺបាត់បង់សម្បទាវិជ្ជាជីវៈអាចត្រូវដាក់អោយចូលនិវត្តន៍ បើសាម៉ីខ្លួនបំពេញលក្ខខ័ណ្ឌដើម្បីទទួលប្រាក់សោធននិវត្តន៍ រឺបញ្ឈប់ពីការងាររាជការក្នុងករណីមិនគ្រប់លក្ខខ័ណ្ឌដើម្បីទទួលប្រាក់សោធននិវត្តន៍ ។

## មាត្រា ៤០.

ទណ្ឌកម្មខាងវិន័យមានដូចតទៅ ៖

១- ទណ្ឌកម្មថ្នាក់ទី ១

ក- ស្តីបន្ទោស

ខ- ស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ- ផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ

ឃ- លុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ រឺថ្នាក់

២- ទណ្ឌកម្មថ្នាក់ទី ២

ក- ស្តីបន្ទោសជាទម្ងន់បណ្តាលអោយលុបចេញពីតារាងឡើងឋានន្តរស័ក្តិ រឺថ្នាក់ បើសិនជាមានចុះឈ្មោះហើយ រឺធ្វើអោយយឺតក្នុងការតំលើងឋានន្តរស័ក្តិ រឺថ្នាក់ក្នុងថេរៈវេលាមួយមានកំណត់ តែមិនត្រូវអោយលើសពី ២ ឆ្នាំ ក្នុងការតំលើងឋានន្តរស័ក្តិ រឺថ្នាក់តាមវេនជ្រើសរើស រឺតាមវេនអតីតភាព ។

ខ- ដាក់អោយនៅទំនេរគ្មានបៀវត្សមិនអោយលើសពីមួយឆ្នាំ ។

គ- បន្ថយឋានន្តរស័ក្តិ រឺថ្នាក់មួយថ្នាក់ រឺច្រើនថ្នាក់ ។

ឃ- ដាក់អោយចូលនិវត្តន៍មុនកំណត់ រឺបញ្ឈប់ពីការងារដោយបង្ខំ ។

ង- បណ្តេញចេញពីមុខតំណែងរាជការ ។

## មាត្រា ៤១.

ការស្តីបន្ទោសត្រូវធ្វើជាលិខិតផ្ញើទៅសាមីខ្លួន ដោយប្រធានអង្គភាព រឺប្រធានស្ថាប័ន ។

ការស្តីបន្ទោសដែលមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន ការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ និងការលុបឈ្មោះចេញពីតារាងតំលើងឋានន្តរស័ក្តិ រឺថ្នាក់ ត្រូវសំរេចតាមព្រះរាជក្រឹត្យ អនុក្រឹត្យ រឺប្រកាសតាមសេចក្តីរាយការណ៍ពីប្រធានអង្គភាព និងក្រោយពីសាមីខ្លួនបានដោះសា ។

## មាត្រា ៤២.

រាល់ទណ្ឌកម្មខាងវិន័យថ្នាក់ទី ២ ត្រូវសំរេចតាមព្រះរាជក្រឹត្យ អនុក្រឹត្យ រឺប្រកាសក្រោយពីមានយោបល់របស់ក្រុមប្រឹក្សាវិន័យ ។

## មាត្រា ៤៣.

អ្នករាជការដែលត្រូវបន្ថយថ្នាក់ រឺឋានន្តរស័ក្តិ ត្រូវបញ្ឈប់ទៅក្នុងថ្នាក់ថ្មី រឺឋានន្តរស័ក្តិថ្មី ចាប់គិតពីថ្ងៃដែលមានសេចក្តីសំរេចជាផ្លូវការ ។

## មាត្រា ៤៤.

ការបណ្តេញមន្ត្រី រាជការចេញពីមុខតំណែង គឺការដកមុខងារ រឺអំណាច និងឋានន្តរស័ក្តិដែលបានប្រគល់អោយពីមុនដល់មន្ត្រី រាជការនោះ ។ ក្នុងករណីដែលត្រូវលុបចោលនូវសិទ្ធិទទួលប្រាក់សោធននិវត្តន៍ រឺប្រាក់ដែលកាត់ទុកក្នុងបេឡាសោធននិវត្តន៍ នោះត្រូវមានសេចក្តីសំរេចជាលាយលក្ខណ៍អក្សរ ។

## មាត្រា ៤៥.

ការចោទប្រកាន់អំពីកំហុសខាងវិន័យ ត្រូវធ្វើដោយសេចក្តីសំរេចរបស់ថ្នាក់គ្រប់គ្រងដែលមានសមត្ថកិច្ចក្រោយពីមានសេចក្តីរាយការណ៍ពិស្តារពីប្រធានអង្គភាព រឺប្រធានស្ថាប័ន ។

## មាត្រា ៤៦.

អនុក្រឹត្យ ឬប្រកាសដែលសំរេចចោទប្រកាន់អំពីកំហុសខាងវិន័យនាំអោយមានការផ្អាកមុខងារនៃអ្នករាជការនោះជាបណ្តោះអាសន្ន តែមិនមានការបន្ថយបៀវត្សទេ ។ ក្នុងរយៈពេលមួយខែយ៉ាងយូរ ក្រុមប្រឹក្សាវិន័យត្រូវកោះប្រជុំដើម្បីផ្តល់យោបល់ ។

សេចក្តីសំរេចផ្អាកការងារអ្នករាជការអោយឈប់ពីតំណែងមានកំណត់ត្រឹម៣ខែ ប៉ុន្តែបើជាករណីពិសេសអាចសំរេចអោយបន្តជាថ្មីទៀតបាន កំណត់ ០១ ខែម្តង ប៉ុន្តែការបន្តនោះមិនត្រូវលើសពី ៣ ដងឡើយ ។

## មាត្រា ៤៧.

ការចោទប្រកាន់អំពីកំហុសខាងវិន័យ ត្រូវធ្វើការអង្កេតជាមុនសិនចំពោះទណ្ឌកម្មខាងវិន័យថ្នាក់ទី២ ។ ការអង្កេតត្រូវប្រគល់អោយតំណាងប្រធានស្ថាប័នសាមីមួយរូប រឺច្រើនរូប ដែលមានឋានន្តរសក្តិ និងថ្នាក់ខ្ពស់ជាង រឺអតីតភាពច្រើនជាងអ្នករាជការដែលត្រូវជាប់ចោទ ។

សំណុំរឿងអង្កេតត្រូវបញ្ជូនទៅប្រធានស្ថាប័នដើម្បីពិនិត្យ និងសំរេចថាគួរបញ្ជូនអ្នករាជការជាប់ចោទនោះទៅអោយក្រុមប្រឹក្សាវិន័យ រឺក៏សំរេចថាគួរបញ្ឈប់ការចោទប្រកាន់វិញ ។ ក្នុងករណីដែលប្រធានស្ថាប័នយល់ថា គួរបន្តការចោទប្រកាន់ សំណុំរឿងត្រូវបញ្ជូនទៅក្រុមប្រឹក្សាវិន័យដែលត្រូវអញ្ជើញអ្នករាជការជាប់ចោទមកពន្យល់ដោះសាដោយផ្ទាល់មាត់ និងជាលាយល័ក្ខណ៍អក្សរមុននឹងក្រុមប្រឹក្សាវិន័យធ្វើការសន្និដ្ឋានអំពីកំហុស និងទណ្ឌកម្ម ដើម្បីជាយោបល់ដល់ថ្នាក់មានសមត្ថកិច្ចសំរេច ។

## មាត្រា ៤៨.

ក្រុមប្រឹក្សាវិន័យ ត្រូវមានសមាជិក ៥ នាក់ ៖

- អ្នករាជការ ៣ នាក់ ចាត់តាំងដោយប្រធានស្ថាប័ន ដែលអ្នករាជការជាប់ចោទនោះនៅក្រោមឱវាទ ម្នាក់បំពេញមុខងារជាប្រធាន និងម្នាក់ទៀតបំពេញមុខងារជាអ្នកធ្វើរបាយការណ៍ ។
- អ្នករាជការ ២ នាក់ ដែលនៅក្នុងក្របខ័ណ្ឌជាមួយគ្នា និងអ្នករាជការជាប់ចោទ ក៏ប៉ុន្តែមានឋានន្តរសក្តិខ្ពស់ជាង រឺមានអតីតភាពការងារចាស់ជាងក្នុងថ្នាក់ស្មើគ្នា ។

មិនអាចចាត់តាំងអោយចូលក្នុងក្រុមប្រឹក្សាវិន័យនេះបាន អ្នករាជការណាដែលជាអ្នកធ្វើពាក្យបណ្តឹងចំពោះអ្នករាជការជាប់ចោទ រឺជាក្រុមញាតិរហូតដល់ជួរទី ៣ របស់អ្នករាជការជាប់ចោទនោះ ។

## មាត្រា ៤៩.

អ្នកធ្វើរបាយការណ៍មានភារកិច្ចប្រាប់ទៅអ្នករាជការជាប់ចោទនូវសិទ្ធិរបស់អ្នករាជការនោះដូចតទៅ ៖

១- សិទ្ធិសុំមើលសំណុំរឿងផ្ទាល់ខ្លួន

២- សិទ្ធិសំអាងសាក្សី

៣- សិទ្ធិជ្រើសរើសតំណាងការពារខ្លួន

៤- សិទ្ធិពន្យល់ដោះសាជាលាយល័ក្ខណ៍អក្សរ រឺដោយផ្ទាល់មាត់ ។

**មាត្រា ៥០.**

ក្រោយពេលបានទទួលរបាយការណ៍ ក្រុមប្រឹក្សាវិន័យអាចបង្គាប់អោយអ្នកធ្វើរបាយការណ៍រកពត៌មានបន្ថែមទៀតបាន ។

ប្រធានអាចពន្យាលពេលប្រជុំក្រុមប្រឹក្សាវិន័យទៅថ្ងៃក្រោយបាន ព្រមទាំងអាចចាត់វិធានការផ្សេងៗដែលមានសារប្រយោជន៍ដើម្បីរកការពិត និងកុំអោយប៉ះពាល់ដល់សេចក្ដីវិនិច្ឆ័យរបស់តុលាការ ក្នុងករណីដែលតុលាការបានសំរេចជាមុនមកហើយ ។

នីតិវិធីនៃការអនុវត្តវិន័យនឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាយាទថ្លៃអោយយក
## មាយាទថោកអោយចៀស




# ចរិតមនុស្ស និង សីលចរិត

## Le caractère humain et son caractère moral

ចរិតមនុស្ស គឺជាការបូកសរុបចំនុចពិសេសនៃផ្លូវចិត្ត និង សារជាតិរបស់មនុស្ស ។ មនុស្សម្នាក់ៗសុទ្ធតែមានចរិតផ្ទាល់របស់គេ ។

នៅពេលកើតមកហើយ មនុស្សមិនគ្រាន់តែរស់នៅក្នុងគ្រួសាររបស់ខ្លួនប៉ុណ្ណោះទេ គឺថែមទាំងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនៅក្នុងសង្គម និងក្នុងបរិស្ថានទៀតផង ។ កត្តានេះ នាំអោយចរិតមនុស្សមានខ្លឹមសារពីរយ៉ាង គឺខ្លឹមសារផ្លូវចិត្ត និង ខ្លឹមសារសង្គម ។

ខ្លឹមសារផ្លូវចិត្ត មានតំរូវការផលប្រយោជន៍ និងទំនោរ ។ ខ្លឹមសារសង្គមមានទំនាក់ទំនងអន្តរកម្មរវាងមនុស្ស និង សង្គម រវាងមនុស្ស និង បរិស្ថាន ។

នៅក្នុងនិន្នាការមួយ ចរិតអាចកើតឡើងឯកឯង ។ ប៉ុន្តែនិន្នាការនេះ អាចប្រែប្រួលទៅតាមបរិយាកាសការអប់រំ និង លក្ខខណ្ឌជីវភាពប្រចាំថ្ងៃ ។ មនុស្សពិតជាមាននិស្ស័យពីកំណើតមែន តែនិស្ស័យនោះ មិនអាចរីកចំរើនទេ ប្រសិនបើគ្មានការអប់រំ ។

*ឧទាហរណ៍* : សិស្សម្នាក់ មាននិស្ស័យខ្ពស់ខាងសិល្បៈតន្ត្រី ។ គេអាចនឹងក្លាយទៅជាតន្ត្រីករយ៉ាងល្បីល្បាញ ប្រសិនបើមានកម្មវិធីបណ្តុះបណ្តាល និងគ្រូឯកទេសខាងមុខវិជ្ជានេះដឹកនាំបានល្អ ។

សីលចរិតរបស់មនុស្ស (le caractère moral de l'homme) មានតួនាទីដ៏សំខាន់ក្នុងសង្គម ។ មនុស្សគ្រប់រូប មានចរិតខុសៗគ្នា ។ អ្នកខ្លះក្លាហាន អ្នកខ្លះព្រហើន អ្នកខ្លះកំសាក អ្នកខ្លះចិត្តល្អ អ្នកខ្លះចិត្តអាក្រក់ ...។ល។ មនុស្សល្អ ជាមនុស្សប្រកបដោយសីលធម៌ រឺប្រកបដោយសីលចរិត ។ សីលធម៌ជាខ្លឹមសារសំខាន់របស់មនុស្ស ។ អ្នកប្រព្រឹត្តអំពើអសីលធម៌ កាប់សំលាប់ ត្រូវបានសង្គមចាត់ទុកថា គេបាត់បង់ភាពជាមនុស្ស (état de l'homme) ។

សីលឆន្ទៈរបស់មនុស្ស (la volonté morale de l'homme) សំរាប់រំដោះមនុស្សអោយផុតពីទំនាក់ទំនងហេតុផល (causalité) ដែលមានលក្ខណៈឯងឹតឯងល់ ដើម្បីឈានទៅដល់សេរីភាពបរិបូរណ៍ ។

*ឧទាហរណ៍* : បើយើងបោះថ្មមួយដុំទៅលើ ថ្មនោះពិតជានឹងធ្លាក់មកវិញភ្លាម ដោយសារកំលាំងទំនាញ






**ក. ឆ.** - គណៈកម្មាធិការនាយក ស.ប.ស.ខ មានបីតិសោមនស្សរីករាយជាទីបំផុត ដោយបានទទួលកំណាព្យពីសមាជិកាមួយរូប គឺអ្នកស្រី គង់ ណារី ជាសាស្ត្រាចារ្យផ្នែកអក្សរសាស្ត្រខ្មែរ ទទួលបន្ទុកបណ្ដុះបណ្ដាលផ្នែកសីលធម៌ កំណាព្យ ចំរៀងប្រពៃណី ចំរៀងបុរាណ ចំរៀងសម័យ និងរបាំប្រជាប្រិយ៍ខ្មែរ ប្រចាំអនុវិទ្យាល័យវត្តកោះ (ភ្នំពេញ) ។

ជាកិត្តិយសដ៏ខ្ពង់ខ្ពស់ អ្នកស្រីបានទទួលជ័យលាភី ព្រះសីហនុរាជ្យ ចំនាត់ថ្នាក់លេខ ៣ កាលពីថ្ងៃទី ២២ មករា ១៩៩៦ ក្នុងសម័យប្រលងជ្រើសរើសស្នាដៃនិពន្ធអក្សរសិល្ប៍ខ្មែរ និងកំណាព្យរបស់សមាគមអ្នកនិពន្ធខ្មែរ ។

១ - ប្រទេសចុះថ្កើងរុងរឿងពិត អាស្រ័យគំនិត ៣ កំនត់
ទី១ ប្រជាច្បាស់ប្រាកដ មានធម៌ហ្មត់ចត់ ពេញអង្គប្រាណ ។

២ - តាំងចិត្តគោរពច្បាប់ទំនៀម ជាសរសៃឈាម ញាតិសន្តាន
រៀបរយដោយថ្នាក់លំដាប់ស្ថាន ទៅតាមលំអាន ក្បួនសាស្ត្រា ។

ជា**សកម្មភាពដែលកើតឡើងដោយសភាវគតិ** ( instinct ) ។ យុវជនម្នាក់ ស្ទុះទៅសង្គ្រោះក្មេងនៅក្នុងផ្ទះដែលមានភ្លើងឆេះសន្ធោរសន្ធៅ គឺជាយុវជនដែលមានសេចក្តីក្លាហាន ប្រកបដោយឆន្ទះមោះមុត ។ នេះជា **សកម្មភាពប្រកបដោយវិចារណញ្ញាណ** ។

ភាពជាមនុស្ស ស្ថិតនៅត្រង់ចិត្តស្រឡាញ់មនុស្សផង និងមានការភ្ញាក់រលឹកផង ។ មនុស្សមានសភាវគតិផង និងមានញាណ ( conscience ) ប្រកបដោយគោលបំណងផង ។ គឺញាណនេះហើយ ដែលជាបង្អែកដ៏រឹងមាំសំរាប់សីលធម៌ ។

**តេអូហ្វ្រាស់** ( **THEOPHRASTE :** ៣៧២ - ២៨៧ មុន គ.ស ) ទស្សនវិទូបូរាណសម័យក្រិចពោលថា : « ចរិតជាសញ្ញានៃសីលជីវិត ( la vie morale ) ដែលសង្គមបានផ្តល់ភាពជាមនុស្សអោយដល់មនុស្ស » ។ លោកបញ្ជាក់ថា ចរិតស្តែងអោយឃើញបុគ្គលម្នាក់ៗ មានន័យថា បើគេមានចរិតបែបណា សីលធម៌របស់គេ ក៏បែបនោះដែរ ។

**អារីស្តូត** ( **ARISTOTE** : ៣៨៤ - ៣២២ មុន គ.ស ) ទស្សនវិទូបូរាណសម័យក្រិចពោលថា : « ចរិត និង ឆន្ទះនៃភាពជាមនុស្ស ជាកត្តាពីរដែលស្ថិតនៅក្នុងអង្គឯកភាពមួយ » ។ លោកយល់ថា ចរិតនិងឆន្ទះមានលក្ខណៈប្រហាក់ប្រហែលគ្នា ។ លោកបែងចែកចរិតជាពីរបែបគឺ : ចរិតជឿនលឿន និង ចរិតអន់ថយ ចរិតជឿនលឿននាំអោយមនុស្សមានសេចក្តីក្លាហាន ពុះពារគ្រប់ឧបសគ្គ ។ ចរិតអន់ថយ នាំអោយមនុស្សបាត់បង់ឋាមពល រួញរា ខ្វះសេចក្តីក្លាហាន រស់នៅប្រកបដោយទុដ្ឋិនិយម ។

ក្នុងនាមជាបុគ្គលិកសិក្សា តើត្រូវអប់រំមនុស្សបែបណា ដើម្បីអោយកុលបុត្រ - កុលធីតាកម្ពុជា មានសីលចរិតសក្តិសមជាពលរដ្ឋថ្លៃថ្នូរ ដើម្បីបំរើសង្គមជាតិ ? ពិតណាស់ មិនមែនតែអ្នកអប់រំ ( éducateurs ) ទេដែលត្រូវស្វែងរកចំលើយ ។ គ្រប់ស្ថាប័នទាំងអស់ សុទ្ធតែត្រូវជួយដោះស្រាយបញ្ហានេះ ក្រោមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ការបាត់បង់សីលចរិតខ្មែរ ជាកត្តាមួយក្នុងចំណោមកត្តាទាំងឡាយនៃការបាត់បង់ព្រលឹងជាតិខ្មែរ ។

**ដោយ ឆយ យី ហ៊ាង**

**បណ្ឌិតទស្សនវិជ្ជា**

៣- ពលរដ្ឋមានសិទ្ធិ សេរីភាព  មិនខ្លស់ទាប ពេញរដ្ឋា
រៀនស្ដី រៀនស្ដាប់ច្បាប់សាសនា  កូនចៅសិក្សាបានខ្ជាប់ខ្ជួន ។

៤- រៀនគិត រៀនគូរ រៀនស្លៀកពាក់  រៀនមើលអោយជាក់ទុកជាក្បួន
រៀនធ្វើពលកម្ម កាយមាំមួន  រៀនថែទាំខ្លួន សាងកុសល ។

៥- ទី ២ សេដ្ឋកិច្ចសំបូរសាយ  ប្រជាគ្រប់កាយ ចាយមិនខ្វល់
ចំណេះខ្ពង់ខ្ពស់ បង្កើតផល  ការងារទៅសល់ ធ្វើអោយហើយ ។

៦- កុំទុកអោយនៅដល់ថ្ងៃស្អែក  នាំចិត្តរវេរវែកមិនខានឡើយ
ទូន្មានកូនចៅ កុំកន្តើយ  ស៊ូទៀយអោយហើយ ទាន់ខ្លួនក្មេង ។

៧- ដំណាំស្រូវស្រែ ផ្លែល្ហុតលាស់  ចិត្តមិនជំទាស់តែគឹបកេង
ទ្រព្យធនមិនខ្វះ មិនលលេង  មិនអោយវង្វេង ក្នុងផ្លូវខុស ។

៨- ឧស្សាហកម្ម រីកដុះដាល  ដំណាំគ្រប់កាលពេញសាយសុស
ស្នាដៃប្រជាទាំងស្រី - ប្រុស  លើកស្ទួយសរស់ជាតិខេមរា ។

៩- ទី ៣ ស្រុបទិសច្បាប់ធម្មនុញ្ញ  ប្រជាជំរុញចិត្តហានក្លា
គ្រប់គ្រង បុរី រដ្ឋសីមា  តាមមុខសញ្ញាធម៌ព្រហ្មា ។

១០- ទំនាក់ទំនងក្រៅប្រទេស  មិនអោយមានធ្វេសគ្រប់វេលា
ពូតដៃ កសាងទាំងអស់គ្នា  អន្តរៈ កម្ពុជា មានសាមគ្គី ។

១១- មានមន្ទីរពេទ្យសាលារៀន  សាលាឆទាន គ្រប់ទិសទី
សង់តាមវិថី សួនរមណីយ៍  យុវជននារី ស្នាក់អាស្រ័យ ។

១២- ផ្ទះ ចូរបងប្អូន ខ្មែរអ្នកអាន  ត្រិះរិះគ្រប់ប្រាណ ដោយឈ្លាសវៃ
អប់រំកូនចៅញាតិ ប្រុសស្រី  តាមអត្ថន័យ ខ្ញុំរៀបរាប់ ។

១៣- កុំលើកទំយើ កូនហួសខ្នាត  ប្រឹងប្រែងសង្វាតអោយជាប់លាប់
ដឹកនាំ តំរង់អោយបានគាប់  នោះនឹងមានភ័ព្វភាសនាខ្ពស់ ។

១៤- ប្រទេសត្រូវការស្តារឡើងវិញ  ខ្មែរកុំទោរម្នេញ សាងកេរ្តិ៍ឈ្មោះ
លើកស្ទួយតំកើងជាតិអោយរស់  អង្គរមានយស គាងសាវតារ ។

# មជ្ឈដ្ឋាននៃការអប់រំ

ការងារអប់រំនឹងប្រព្រឹត្តទៅបានល្អប្រសើរ លុះត្រាតែមជ្ឈដ្ឋានទាំងបីប្រទាក់ក្រឡាគ្នា រឺសហប្រតិបត្តិការជាមួយគ្នាយ៉ាងជិតស្និទ្ធស្និតរមួត ។ មជ្ឈដ្ឋានទាំងបីនោះគឺ :

- គ្រួសារ
- សាលារៀន
- សង្គម

## ១-តួនាទីរបស់គ្រួសារ

ជីវភាពរស់នៅរបស់កូនប្រុសស្រីនៅជាប់ជានិច្ចជាមួយឪពុកម្ដាយរហូត « បែកផ្ទះ » គឺចាកចេញពីឪពុកម្ដាយនៅពេលមានប្ដីប្រពន្ធហើយ ។

ដូច្នេះ តួនាទីអប់រំកូន គឺជាបន្ទុកឪពុកម្ដាយក្នុងដំណាក់កាលទី ១ នេះ ។ ឪពុកម្ដាយ ត្រូវតែចេះវិធីខ្លះសំរាប់អប់រំកូន និងចេះរៀបចំគ្រួសារខ្លួនអោយមានជីវភាពសុខដុមរមនា ដើម្បីបានជាជំរកមួយមានសិរីសួស្ដី មិនមានពួពាក្យជេរប្រទេចផ្ដាសា ឈ្លោះប្រកែកគ្នារវាងប្ដី និងប្រពន្ធ ។

កូនតូចៗតាមចរិតវា វាជាអ្នកត្រងត្រាប់ គឺធ្វើតាមទាំងសំដី និងកាយវិការរបស់ឪពុកម្ដាយ រឺបងប្រុសស្រីរបស់វា ។ វាត្រូវការ ការថ្នាក់ថ្នមពីម្ដាយ ពីឪពុក ។ ប៉ុន្តែ ម្ដាយមានតួនាទីសំខាន់ជាង ។

គឺនៅក្នុងក្របខ័ណ្ឌជីវភាពគ្រួសារនេះឯងហើយ ដែលកូនប្រុសស្រីទទួលបានទំលាប់ល្អ រឺអាក្រក់ ។ ផ្ទុយទៅវិញ ក្នុងគ្រួសារដែលប្ដីប្រពន្ធឈ្លោះប្រកែកគ្នា មិនសូវលោះពេលនោះ កូនរកការសប្បាយរីករាយមិនឃើញ ។ គ្រួសាររកសុភមង្គលមិនឃើញ ។ ម្យ៉ាងទៀត ឪពុកបញ្ចេញឫកក្អេងក្អាង ឡូឡានៅមុខកូន នាំអោយកូនខ្លះធ្វើតាម ខ្លះនាំអោយកូនស្អប់ទៅវិញ ។

អាស្រ័យហេតុនេះ គួរតែឪពុកម្ដាយមានឫកពាជាអ្នកអប់រំទើបកូនយកតំរាប់តាម ។

## ២- តួនាទីរបស់សាលារៀន

សាលារៀន ជាឧបករណ៍របស់រដ្ឋមានតួនាទីបណ្ដុះបណ្ដាលកុមារា កុមារី ទៅតាមគោលនយោបាយអប់រំកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងតាមទិសគរុកោសល្យទំនើប ។ គោលនយោបាយអប់រំ កំណត់ខ្លឹមសារអប់រំ ។ បានសេចក្ដីថា គើទស្សនវិស័យអប់រំមានបំណងប្រាថ្នាបណ្ដុះបណ្ដាលកូនខ្មែរ អោយបានជាមនុស្សបែបណា ទៅអនាគត ព្រោះសិស្សដែលចូលរៀនគាលពីអាយុ ៦ ឆ្នាំ នឹងត្រូវទៅជាពលរដ្ឋពេញសិទ្ធិ អាចចេះវិនិច្ឆ័យពីវាសនាជាតិ តាំងពីអាយុ ១៨ឆ្នាំឡើងទៅ ព្រោះគេអាចកាន់សន្លឹកឆ្នោតមួយសន្លឹកទៅបោះក្នុងហិប នៅពេលបោះឆ្នោតរើសតំណាងរាស្ត្រ រឺបោះឆ្នោតរើសប្រធាន

ភូមិ ឃុំជាដើម ។ សិស្សនេះ ត្រូវមានលក្ខណៈសម្បត្តិយ៉ាងណាខ្លះ ដែលកំពុងរស់នៅក្នុងប្រទេសមួយប្រកាន់យកគោលមាគ៌ា នយោបាយប្រជាធិបតេយ្យសេរី ។

ក្រសួងអប់រំ មានភារកិច្ចកំណត់កម្មវិធីអប់រំ ស្របទៅតាមខ្លឹមសារអប់រំ និងរៀបចំតាក់តែងសៀវភៅសិក្សា ស្របទៅតាមកម្មវិធីសិក្សា និងវិក្រឹត្យការលោកគ្រូ អ្នកគ្រូអោយអនុវត្តកម្មវិធីថ្មី ។

តួនាទីសាលារៀន គឺបណ្តុះបណ្តាលពលរដ្ឋអោយមានចំនេះដឹងសំខាន់ៗ ជាមូលដ្ឋាន និងបង្ហាត់បង្រៀនផ្នែកខាងហត្ថពលកម្ម ដើម្បីអោយក្លាយជាពលករដ៏ប៉ិនប្រសប់ បំពេញការងារដោយមានទមសិការគ្រប់គ្រាន់ ។

ដូច្នេះ លោកគ្រូអ្នកគ្រូពិតមែនតែបានទទួលកន្លងមក នូវការបណ្តុះបណ្តាលវិជ្ជាជីវៈខាងគរុកោសល្យ ទៅតាមរបបមួយជាកំណត់ហើយនោះ ក៏ត្រូវគិតសាជាថ្មីឡើងវិញនូវទិសអប់រំតាមគរុកោសល្យទំនើប ដើម្បីឈានទៅដល់គំណាក់កាលមួយថ្មី ។

យើងទាំងអស់គ្នាបានដឹង បានយល់ឃើញថា កន្លងមក យើងបានប្រឹងអស់ពីកំលាំងកាយចិត្ត ស្តារ និងកសាងប្រព័ន្ធអប់រំថ្មីមួយ ។ តែមកដល់បច្ចុប្បន្នកាលនេះ ប្រព័ន្ធអប់រំថ្មីនោះ វាសមស្របទៅតាមកាលៈទេសៈដែររឺទេ ? ទៅតាមគថភាពសង្គមនយោបាយ សេដ្ឋកិច្ចរបស់ប្រទេសយើងដែររឺទេ ?

អាស្រ័យហេតុនេះ ក្នុងឋានៈជាអ្នកអប់រំនៅក្នុងសាលារៀន ព្រមទាំងលោកអ្នកដែលជាប់ចិត្តគិតពីការងារអប់រំកូនចៅដែលយើងទាំងអស់គ្នាកំណត់ថា ជាសសរទ្រូងនៃប្រទេសជាតិនោះ សូមជួយគិតពិចារណាពីការអប់រំនៃប្រទេសកម្ពុជា ដើម្បីរៀបចំកូនខ្មែរអោយយល់ អោយដឹងពីតំលៃដែលពលរដ្ឋខ្មែរម្នាក់ៗត្រូវមាន ។

## ៣. តួនាទីរបស់សង្គម

យើងធ្លាប់បានដឹងជាយូរយារមកហើយថា សង្គមមានតួនាទីអប់រំកុមារា កុមារី ព្រមទាំងមហាជនគ្រប់ជាន់ថ្នាក់ ។

យើងខ្ញុំសូមអស់លោកជាអ្នកអប់រំ ល្បងធ្វើការពិភាក្សាជាមួយគ្នាលើពាក្យថា សង្គមជាមជ្ឈដ្ឋានមួយ រឺជាកត្តាមួយទទួលភារៈជាអ្នកអប់រំ ។ តើសង្គមខ្មែរដែលមានប្រជាជនជាង ៨ លាននាក់នោះ ជាអ្នកអប់រំរឺ ? រឺមួយសង្គមជាតិដទៃទៀត អាចជាកត្តាអប់រំមួយដែរ ? នេះជាបញ្ហាដែលត្រូវគិត ព្រោះកន្លងមក យើងខ្ញុំបានឮដូចលោកគ្រូអ្នកគ្រូដែរថា មជ្ឈដ្ឋានអប់រំ ( milieux éducatifs ) មានបី គឺគ្រួសារ សាលារៀន និងសង្គម ។

តែតាមពិត ប្រហែលជាអស់លោកអ្នកអាន និងអ្នកអប់រំមិនទាន់បានយល់ច្បាស់ស៊ីជំរៅពីសង្គមនេះនៅឡើយទេ ។ មកដល់ត្រង់កន្លែងនេះ សូមអស់លោកបិទសៀវភៅនេះសិន ហើយត្រិះរិះដញ្ជឹងគិតមួយស្របក់ តើរឿងពាក្យសង្គមនេះ វានៅត្រង់ណា ? ចង់និយាយពីអ្វី ?

យើងខ្ញុំសូមឆ្លើយថា សង្គមនៅទីនេះមានធាតុផ្សំពីរ គឺ ៖

- ជីវភាពសង្គម ( Vie sociale )
- ប្រព័ន្ធឃោសនា សារពត៌មាន - ទស្សនាវដ្តី - វិទ្យុទូរទស្សន៍ ( ensemble de médias ) ។

ដូចម្តេចហៅថា ជីវភាពសង្គម ? គឺទំនាក់ទំនងរវាងមនុស្សមួយនាក់ ទៅនឹងសមាជិកដទៃទៀតនៃសមូហភាព

( vie sociale : rapports entre un individu et les autres membres de la collectivité ( Petit Larousse )

សព្វថ្ងៃនេះ សង្គមវិទូបានយល់ឃើញថា លទ្ធផលនៃការងារអប់រំ ត្រូវបានទទួលពីអំពើ រឺពីទំនាក់ទំនងគ្នាច្រើនបែបច្រើនយ៉ាងណាស់ ។ ម្ល៉ោះហើយ គេបង្កើតពាក្យមួយហៅថា សាលាបិទមុខ រឺលាក់មុខ ( école parallèle ) ( កុំច្រឡំប្រែពាក្យនេះថា ស្របគ្នា ) ន័យអត្ថបដិរូបបានសេចក្ដីថា បិទមុខ លាក់មុខ គឺមើលមិនឃើញ ដែលជាធាតុផ្សំទីពីរ ដូចខ្ញុំជំរាបខាងលើ ។

គ្រួសារជាសង្គមតូចមួយក្នុងសង្គមធំ ។ បងប្អូនប្រុសស្រី ឪពុកម្ដាយមានទំនាក់ទំនងល្អជាមួយគ្នា បង្កើតបានជាមជ្ឈដ្ឋានមួយ រឺបរិយការណ៍ ( ambiance ) មួយសុខដុមរមនា ។ បរិយការណ៍នេះ ជះឥទ្ធិពលទៅលើកូននាំអោយមានលំនឹងក្នុងការរៀន និងមិនមានការថ្នាំងថ្នាក់ចិត្ត ។ លុះកូននេះទៅសាលារៀន វាបានទាក់ទងជាមួយសិស្សដទៃទៀត បង្កើតបានមុនដំបូងជាពួកម៉ាក ក្រោយមកជាមិត្តភក្ដិ ។ ក្នុងការទាក់ទងនេះ បើប៉ះទៅមិត្តល្អក៏នាំអោយល្អ បើប៉ះទៅលើមិត្តមិនល្អ ក៏នាំអោយមិនល្អ គឺទៅជាខូចដោយប្រការផ្សេងៗ ។ លុះសិស្សយើងពេញវ័យ ត្រូវបានចូលទៅប្រកបការងារនៅក្នុងស្ថាប័នរដ្ឋ រឺឯកជនណាមួយ ។ សមូហភាពនៃស្ថាប័ននោះ តែងតែមានឥទ្ធិពលមកលើអ្នកចំណូលថ្មី ។ អ្នកចំណូលថ្មីនេះ មានមិត្តភក្ដិស្និទ្ធស្នាលជាមួយអ្នកនេះ រឺអ្នកនោះ ប្រសិនបើស្និទ្ធស្នាលទៅលើបុគ្គល មានអាកប្បកិរិយាប្រកបដោយចរិយាធម៌នោះ ជាការគាប់ប្រសើរ ។ ផ្ទុយទៅវិញ គេនាំប្រព្រឹត្តអំពើពាលាអាវ៉ាសែផ្សេងៗ នាំអោយបែកបាក់គ្រួសារ នាំអោយកូនចៅរងទុក្ខវេទនាគ្រប់បែបយ៉ាង ។

កត្តាមួយទៀត ដែលជាធាតុផ្សំទី២ នៃសាលាបិទមុខ គឺសារពត៌មាន ទស្សនាវដ្ដី វិទ្យុ និងទូរទស្សន៍ ដែលជាប្រព័ន្ធឃោសនា និងអប់រំ ។ ប្រព័ន្ធនេះសំខាន់ណាស់ ។ សព្វថ្ងៃនេះ នៅប្រទេសកម្ពុជាយើង ទស្សនាវដ្ដីសារពត៌មាន មិនសូវមានខ្លឹមសារអប់រំកូនចៅ និងមហាជនឡើយ ។ ភាពយន្ត និងវីដេអូ បរទេស និងខ្មែរ ជាឧបករណ៍រកកំរៃ ។ គេផលិតដើម្បីរកកំរៃ ។ គេតំរូវទៅតាមចំណង់ចំណូលចិត្តសាធារណជនខ្មែរ ដែលចូលចិត្តតែរឿងកំសត់ ព្រាត់ប្រាស់ និង ស្នេហា ។ ល ។ រឺឯភាពយន្តបរទេសខ្លះវិញ មានឥទ្ធិពលមិនល្អមកលើសីលធម៌សង្គមខ្មែរដែរ ។

ជាសរុប យើងឃើញថា ការទាក់ទងកត្តាអប់រំទាំងបីខាងលើ មានភាពស្អិតល្មួតនឹងគ្នាណាស់ វាត្រូវដើរព្រមគ្នាទៅតាមខ្លឹមសារអប់រំ ។ បើមិនដូចនេះទេ ការអប់រំកុលបុត្រ កុលធិតាមិនបានល្អ រឺ មិនមានប្រសិទ្ធភាព ។ ការទប់ខ្លួនកុំអោយធ្លាក់ទៅក្នុងអបាយមុខជាការពិបាក ព្រោះការចង់សប្បាយ ចង់មានបាន ចង់ហ៊ឺហា វាចេះតែមកបាំងមនសិការ ។ ឧទាហរណ៍ អ្នករដ្ឋការម្នាក់ កាលនៅជានិស្សិត មានកិរិយាមារយាទល្អណាស់ សឹងទុកជាផនតំរូ ។ លុះចូលមកបំរើការងាររដ្ឋប្រហែលបាន ៣ រឺ ៤ ឆ្នាំ អ្នករាជការនោះ ទប់ខ្លួនមិនបាន ព្រោះមិត្តជិតស្និទ្ធក្នុងសមូហភាពនោះចេះតែបបួលទៅណេះទៅណោះ លុះត្រាតែធ្លាក់ខ្លួនទៅជាអ្នកលេងល្បែង ស៊ីផឹក លេងតិតប្រពន្ធកូន ។

ចូរយើងក្រឡេកមើលស្ថានភាពអប់រំនៅកម្ពុជាយើងសព្វថ្ងៃ ទាំងនៅទីក្រុង និងជនបទ ។ តើកត្តាអប់រំទាំងបីនេះ ដើរស្របគ្នាដែររឺទេ ? នរណាទទួលភារៈអប់រំ ។ សូមជំរាបថា កត្តាទាំងបីនេះ មិនមានសមតា ( équilibre) ស្មើគ្នាទេ ។ កាលនៅក្នុងវ័យកុមារ គ្រួសារមានតួនាទីអប់រំកូនធំជាងសាលារៀន និងសាលាបិទមុខ ។ លុះកូននេះចូលរៀននៅសាលាបឋមសិក្សា និង មធ្យមសិក្សា ដំណាក់កាលអប់រំចែកជាពីរ ៖

- គ្រួសារនៅមានឥទ្ធិពលដដែល តែមានតួនាទីគាន់តែខ្សោយទៅៗជាលំដាប់ ។

ឥទ្ធិពលនៃសាលារៀនកាន់តែធំ និង សាលាបិទមុខក៏ចាប់មានសារៈសំខាន់ ។

- តួនាទីអប់រំរបស់គ្រួសារថយចុះ ។ វាត្រូវបានទទួលឥទ្ធិពលពីសាលាបិទមុខមកវិញ ។ សាលារៀននៅមានឥទ្ធិពលដដែល តែចាប់ថយបន្តិចម្តងៗ ។

កាលណាសិស្ស រឺកូននេះ រៀនចប់មធ្យមសិក្សា ហើយចូលទៅរៀននៅមហាវិទ្យាល័យ រឺចូលបំពេញការងារអ្វីមួយ សមូហភាពនិស្សិត រឺនិយោជិតរោងចក្រ សហគ្រាសនោះ មានឥទ្ធិពលលើនិស្សិត រឺនយោជិតយើង ។ ឥទ្ធិពលគ្រួសារថយចុះមួយកំរិតធំ ។

តាមការសង្កេតរបស់ខ្ញុំ នៅប្រទេសកម្ពុជាយើង ជាទូទៅតួនាទីរបស់កត្តាអប់រំទាំងបីពុំទាន់មានកំរិតសមស្របនៅឡើយ ។ គេបណ្តោយអោយកូនចៅរស់ទៅតាមធម្មជាតិ ។ កូនធ្វើអំពើអ្វីមួយខុសឆ្គង ទើបគេចាប់ប្រដៅប្រដៅ ជួនកាលដោយខឹងពេក ឪពុកម្តាយវាយកូនតែម្តង ។ នេះជាអំពើមួយឆ្គាំឆ្គង ។ គេថា ទុកវាអោយសោយរាជ្យអ្វី បើមិនវាយវា ។ គេថា ត្រូវពត់វាទាន់វានៅក្មេង តែកាលណាវារឹងពត់លែងបានហើយ ។ តើពត់ដោយវិធីណា ? នេះជាបញ្ហាដែលឪពុកម្តាយត្រូវដឹង ។

មានឪពុកម្តាយខ្លះទិតៀនគ្រូ ។ កូនធ្វើខុសអ្វីមួយ ស្រែកជេរកូនថា គ្រូឯងប្រដៅអោយធ្វើអញ្ចឹងរឺ ? គ្រូឯងឥតប្រដៅទេរឺ ? នេះជាបញ្ហាមួយទៀត ព្រោះគាត់ធ្វើព្រងើយលែងចង់ទូន្មានកូន ។

រីឯសាលាបិទមុខវិញ ឪពុកម្តាយហាក់ដូចជាអស់ឥទ្ធិពល ។ កូនមើលសៀវភៅរឿង មានគំនូរដែលលក់ពាសពេញនៅទីក្រុង និងនៅទីប្រជុំជនធំៗ តើសៀវភៅនេះ គួរអនុញ្ញាតអោយអានរឺទេ ? វីដេអូមិនសមរម្យនិងភ្នែក តើមានហាមប្រាមកុំអោយមើលរឺទេ ? រឺអោយកូនទៅជួលវីដេអូកាស្សែតរឿងនេះ រឿងនោះទៅវិញ ព្រោះខ្លួនចង់មើលដែរ ព្រោះមានក្រុមកាប់ដាវសំដែងរិទ្ធិ ។

តាមមតិខ្ញុំ គួរតែរដ្ឋពិចារណារឿងទាំងអស់នេះឡើងវិញ ។ គួរតែកែចិត្តគំនិតប្រជាជនអោយយល់អំពីការអប់រំកូនចៅទៅអនាគត ។ ដូច្នេះ គឺមិនមានអ្វីក្រៅពីមជ្ឈដ្ឋានទាំងបីនេះទេ ដែលមានតួនាទីសំខាន់សំរាប់អប់រំកូនចៅ ។

យើងខ្ញុំសូមសង្ឃឹមញញឹមទុកជាមុនថា ក្រោមការដឹកនាំដ៏ភ្លឺស្វាងរបស់រាជរដ្ឋាភិបាលបច្ចុប្បន្ន ការងារអប់រំនឹងប្រព្រឹត្តទៅបានល្អ ដោយមជ្ឈដ្ឋានទាំងបីយល់ច្បាស់ទិសអប់រំកុលបុត្រ កុលធីតាដែលជាសសរទ្រូងរបស់ប្រទេស ។

**ដោយ យ៉ន់ ធី**

## ចិត្តមិនអប់រំ នាំអោយវិនាស

# តើអប់រំកុមារដូចម្ដេច?

នាបច្ចុប្បន្នកាលនេះ ប្រទេសកម្ពុជា ស្ថិតនៅក្នុងរបបនយោបាយមួយ គ្រប់គ្រងដោយរដ្ឋធម្មនុញ្ញ ដែលត្រូវបានសភាធម្មនុញ្ញអនុម័ត កាលពីថ្ងៃ ២១ កញ្ញា ១៩៩៣ ។

ក្នុងច្បាប់គោលនេះ បញ្ហាអប់រំវប្បធម៌ និងសង្គមកិច្ច ( ជំពូកទី ៦ ) បានលើកឡើងជាទិសអនុវត្តចំពោះរដ្ឋាភិបាល ។

ក្រសួងអប់រំ ជាស្ថាប័នរដ្ឋមួយ ក្នុងចំណោមស្ថាប័ននានា ដែលមានតួនាទីអប់រំប្រជាពលរដ្ឋទូទាំងប្រទេស ទាំងចាស់ ទាំងក្មេង ។

ការអប់រំ គឺជាទង្វើមួយ ធ្វើអោយមនុស្សក្លាយជាមនុស្សពិតប្រាកដ ពោលគឺ :

១ - ធ្វើយ៉ាងណាអោយមនុស្ស ចាប់ពីបានឃើញពន្លឺថ្ងៃមក ទទួលនូវការអប់រំល្អ (bonne éducation) អំពីឪពុកម្ដាយ ហើយបន្តបន្ទាប់មកពី គ្រូបាធ្យាយ ចាស់ព្រឹទ្ធាចារ្យ និងពីសមូហភាព ។ល។ បង្ហាត់បង្រៀនយ៉ាងណា អប់រំយ៉ាងណាអោយមនុស្សនោះខិតខំហាត់ពត់លត់ដំខ្លួន អោយបានជាមនុស្សមានតំលៃ រឺយល់ដឹងពីតំលៃរបស់មនុស្ស << la valeur de l'homme >> រឺសេចក្ដីថ្លៃថ្នូររបស់មនុស្ស la dignité de l'homme ។

មនុស្សមានតំលៃ មានចរិតលក្ខណៈអ្វីខ្លះ ?

ក - មានចំណេះដឹង មានបញ្ញាវៀងវៃ ចេះត្រិះរិះពិចារណា ថ្លឹងថ្លែងរកខុសរកត្រូវ

ខ - មានសមត្ថភាព (compétence) ក្នុងការងារ និង កំលាំងឆន្ទៈដ៏ខ្លាំងក្លា

គ - មានសីលធម៌ និង គុណធម៌ ដែលជាតំលៃធំចំបង លើសតំលៃទាំងពីរខាងលើ ។ ខ្វះសីលធម៌ គុណធម៌ ជាមនុស្សមិនមានតំលៃ ។ ភាពថ្លៃថ្នូរ ក៏សាបរលាបបាត់បង់ទៅជាមួយគ្នាដែរ ។

២ - បណ្ដុះបណ្ដាលមនុស្ស អោយបានជាពលរដ្ឋល្អ (un bon citoyen) ។

ចំពោះគោលដៅនេះ ការអប់រំមិនគ្រាន់តែបង្ហាត់បង្រៀនពីស្ថាប័នគ្រប់គ្រងរដ្ឋពីមជ្ឈិម ដល់មូលដ្ឋាន និងអំណាចទាំងបី : នីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ ប៉ុណ្ណោះទេ ។ សំណូមពរនៃការអប់រំគឺចង់បានពលរដ្ឋមានអត្តសញ្ញាណជាតិដក់នៅក្នុងក្រអៅបេះដូង មានឆន្ទៈបំរើជានិច្ចនូវផលប្រយោជន៍ជាតិ ដោយមិនគ្រាន់តែសច្ចាប្រណិធានប៉ុណ្ណោះទេ ។ ការអប់រំពលរដ្ឋវិទ្យា (éducation civique) ទាមទារជាដាច់ខាតបង្កើតអោយបាននូវមនោសញ្ចេតនាជាតិ នូវការអនុវត្តន៍អោយបានត្រឹមត្រូវល្អ នូវសិទ្ធិ និង ករណីយកិច្ចរបស់ពលរដ្ឋ ។

៣ - បណ្ដុះបណ្ដាលពលរដ្ឋ អោយមានសមត្ថភាពក្នុងការងារចិញ្ចឹមជីវិត និង អភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចជាតិ អោយមានវឌ្ឍនការជាលំដាប់ ។ រួមចំណែកធ្វើអោយមនុស្សជាតិស្គាល់ និងរក្សានូវសន្តិភាព ស្រឡាញ់សន្តិភាព សេរីភាព វឌ្ឍនភាព និង ការយោគយល់គ្នាទៅវិញទៅមក ។

ចំនុចធ្ងរមធំទាំងបី ត្រូវបានចង្អុលបង្ហាញហើយ តើក្រសួងអប់រំ រឺអ្នកអប់រំត្រូវធ្វើអ្វីទៀត ? ចំលើយ គឺរិះរកមធ្យោយ វិមាតិដែលត្រូវប្រកាន់យក ដើម្បីធ្វើដំណើរឆ្ពោះទៅដល់គោលដៅ ។

នេះជាចំណុចដ៏ពិបាកដោះស្រាយ ក្នុងស្ថានភាពដ៏ស្មុគស្មាញ សាំញ៉ាំនៃប្រទេសកម្ពុជានាបច្ចុប្បន្ន ដែលកំពុងឆ្លងកាត់នូវវិបត្តិដ៏ធ្ងន់ធ្ងរនៅគ្រប់វិស័យ សេដ្ឋកិច្ច សង្គម វប្បធម៌ និង ចរិយាធម៌ ។

តាមគំនិតខ្ញុំ ខ្ញុំយល់ឃើញថា យើងអាចដោះស្រាយវិបត្តិទាំងឡាយនេះបាន ដោយនៅដំណាក់ដំបូង ប្រជាពលរដ្ឋចាប់ពីថ្នាក់លើ ដល់ថ្នាក់ក្រោម ត្រូវប្រតិបត្តិតាមក្រមសីលធម៌ (Code de morale) ទាំងអស់គ្នា ។ ជាបឋម រដ្ឋាភិបាលត្រូវបំផុសផ្សព្វផ្សាយ និងធ្វើអោយរស់ឡើងវិញនូវសីលធម៌ខ្មែរ ទស្សនវិជ្ជាខ្មែរ គតិបណ្ឌិតខ្មែរ និងព្រលឹងដ៏បរិសុទ្ធពិតត្រង់របស់ខ្មែរ ដែលបែកបាក់ដោយសង្គ្រាម ។ ហេតុអ្វី បានជាធ្វើការងារនេះ ? ពីព្រោះ ការផ្លាស់ប្តូរ រឺការកែប្រែចិត្ត និងគំនិត (Changement de mentalités) ជាការលំបាក ទាមទារពេលវេលាដ៏វែង គឺប្រហែលមួយជំនាន់មនុស្ស ( ជាង ៣០ ឆ្នាំ ) ។ ខ្ញុំលើកកត្តាពេលវេលានេះ គឺដើម្បីចង់បង្ហាញថា អ្នកអប់រំខាងផ្នែកនេះ ត្រូវមានធម៌ខន្តី អត់ធ្មត់ មានសេចក្តីសប្បាយរីករាយ នឹងទង្វើដ៏ល្អប្រសើរនេះ គឺចៀសវាងភ្លើងចំបើង មានឆន្ទៈដ៏មុត និងកម្មវិធីត្រឹមត្រូវ រៀបចំទៅតាមដំណាក់កាល ។ ឧទាហរណ៍ : ដំណាក់កាលនេះ គឺជាការកសាងសន្តិភាព ស្ថេរភាពនយោបាយ បំបាត់គំនិតអត្តទត្ថ ចិត្តលោភលន់ ចង់មាន ចង់បានតែម្នាក់ឯង និងចិត្តហឹង្សា គ្មានធម៌សន្តោសប្រណី ។

ទន្ទឹមនឹងការបំផុសចលនានេះ សិស្សានុសិស្ស ត្រូវអប់រំគេដូចម្តេច ? ជាការពិតណាស់ បើបរិដ្ឋានសង្គមល្អហើយខាងផ្នែកសីលធម៌ ការអប់រំក្នុងសាលារៀនទៅតាមនោះដែរ ។ បរិដ្ឋានសង្គម (environnement social) ជាសមាសភាគមួយ ក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស ។

**ដោយ យ៉ង់ ធី**



# គរុកោសល្យ & ការគ្រប់គ្រង

# ការបណ្ដុះបណ្ដាលពីចំងាយ

## ហេតុអ្វីបានជាមានការបណ្ដុះបណ្ដាលពីចំងាយនៅព្រះរាជាណាចក្រកម្ពុជា

- គឺដោយការយកចិត្តទុកដាក់របស់ក្រសួងអប់រំ យុវជន និងកីឡា ចំពោះការលើកកំពស់គុណភាពអប់រំ ។

អាស្រ័យហេតុនេះ គណៈកម្មការបច្ចេកទេសមួយត្រូវបានបង្កើតឡើង ដោយមានភារកិច្ចនិពន្ធ និងរៀបរៀងឯកសារបណ្ដុះបណ្ដាលពីចំងាយ ដើម្បីបំប៉នគ្រូបឋមសិក្សាចំពោះមុខវិជ្ជា ភាសាខ្មែរ និង គណិតវិទ្យា ក្រោមការឧបត្ថម្ភនៃកម្មវិធីទ្រទ្រង់ផ្នែកអប់រំបឋមសិក្សានៅកម្ពុជារបស់សហភាពអឺរុប << PASEC >> ។

យើងម្នាក់ៗ បានដឹងហើយថា កាលពីប៉ុន្មានឆ្នាំកន្លងមកនេះ កំរិតចំនេះដឹងក្នុងការជ្រើសរើសគ្រូមិនបានស្មើគ្នាទេ ដោយមកពីតំរូវការធំធេងណាស់សំរាប់បំពេញចំនង់ចង់ចេះ ចង់ដឹងរបស់កុមារកុមារី ដែលសំរុកចូលសាលារៀនក្រោយឆ្នាំ ១៩៧៩ ។ ការបណ្ដុះបណ្ដាលគរុកោសល្យបន្ទាប់ពីការជ្រើសរើសជាហូរហែមក ក្រោមរូបភាពកម្មសិក្សា មិនទាន់មានប្រសិទ្ធិភាពតាមសំទុះនៃអភិវឌ្ឍន៍ឡើយ ។ ហេតុនេះ គុណភាពអប់រំបានធ្លាក់ចុះដែលគួរអោយចាប់អារម្មណ៍តាំងពីកាលនោះមក ។

លុះមកដល់ដើមឆ្នាំ ១៩៩០ ទើបក្រសួងអប់រំចាប់មានកង្វល់លើការលើកកំពស់គុណភាពអប់រំ ។ នៅពេលនោះ ក្រសួងបានអំពាវនាវចំពោះអង្គការអន្តរជាតិ មិនមែនរដ្ឋាភិបាលអោយជួយកសាងប្រព័ន្ធអប់រំឡើងវិញ និងជួយលើកកំពស់គុណភាពអប់រំ ។

ដោយការបណ្ដុះបណ្ដាលពីចំងាយក្នុងពេលគ្រូកំពុងបំរើការមិនមានឡើយ ទើបអង្គការមួយហៅ << ប៉ាសិច >> បានស្ម័គ្រជួយលើកកំពស់ចំនេះដឹងគ្រូបឋមសិក្សាដោយឆ្លងតាមការបណ្ដុះបណ្ដាលពីចំងាយ កាលពីឆ្នាំ ១៩៩៥ ។

## I- ដំណាក់កាលទី ១ នៃការបណ្ដុះបណ្ដាលពីចំងាយ

ចាប់តាំងពីខែ មករា ១៩៩៥ មក គណៈកម្មការបច្ចេកទេស បានតាក់តែងឯកសារបានប្រាំមួយភាគហើយ ដោយអនុវត្តតាមទិសដៅពីរ គឺ ៖

១- ការលើកកំពស់ចំនេះដឹងគរុកោសល្យគ្រូអោយបានស្មើនិយាមកំនត់ ។

២- ការយកចំនេះដឹងនោះទៅបង្រៀនសិស្ស

ឯកសារទាំងអស់នេះ ត្រូវបានបញ្ជូនទៅអោយលោកគ្រូទាំង ៤៥.០០០ នាក់ ដែលជាអ្នកមានសិទ្ធិត្រូវទទួលការបំប៉ន ។ ក្នុងឯកសារនីមួយៗ មានលំហាត់ស្វ័យកំនែ និងមានកិច្ចការដែលគ្រូត្រូវធ្វើដើម្បីជាមធ្យោបាយសំរាប់វាយតំលៃនៃការទទួលចំនេះដឹង ។ នៅតាមភូមិភាគរដ្ឋបាលនីមួយៗ មានអ្នកជំនួយការបច្ចេកទេសរបស់ប៉ាសិច ទទួលបន្ទុកគ្រប់គ្រងការងារបណ្តុះបណ្តាល មានការនាំយកជំនួយហិរញ្ញវត្ថុផ្តល់អោយគ្រូ និងមានការតាមជួយណែនាំដោយគ្រូឧទ្ទេសនៅតាមទីកន្លែងផ្ទាល់ ។ ការងារគ្រប់គ្រងនេះ សំដៅជួយគ្រូក្នុងការស្វ័យសិក្សាពីចំងាយអោយមានប្រសិទ្ធិភាព ។

## II - ដំណាក់កាលទី ២ នៃការពង្រឹងការបណ្តុះបណ្តាលពីចំងាយ

ដោយបានទទួលយកមកពិចារណានូវកំនត់សំគាល់ និងការរិះទៀនស្ថាបនាសមហេតុផលរបស់គ្រូយើងទៅលើឯកសារទាំងប្រាំមួយនោះ គណៈកម្មការបច្ចេកទេសបានសំរេចរៀបចំអោយមានទំរង់មួយថ្មី ចាប់ពីឯកសារលេខ៧ តទៅ ។ ខ្លឹមសារនៃឯកសារនេះ មានការវិវត្តន៍ឈានឡើងយ៉ាងធំធេងប្លែកពីឯកសារមុនៗ ដោយគណៈកម្មការបច្ចេកទេសរៀបចំជូនគ្រូនូវសលាកប័ត្រគរុកោសល្យតាមកំរិតថ្នាក់ ហើយមានលក្ខណៈងាយស្រួលយកទៅបង្រៀនផ្ទាល់បានតែម្តង ។

ការទំលាប់ប្រើវិធីសាស្ត្រថ្មី និងការស្វែងយល់លើខ្លឹមសារថ្មីប្លែកនេះ គ្រូយើងនឹងឈានទៅដល់គោលដៅកំនត់ គឺការប៉ិនប្រសប់ វិសមត្ថភាពខ្ពស់ក្នុងការបង្រៀន ។

ការបណ្តុះបណ្តាលតាមបែបថ្មីនេះមានអនុភាពខ្ពស់ទៅលើការដឹកនាំមេរៀន និងទៅលើការទទួលបានចំនេះដឹងដែលអាចវាស់បានឆ្លងតាមលទ្ធផលសិស្ស ។

## III - ហេតុអ្វីបានជាគណៈកម្មការបច្ចេកទេសសំរេចយកការរៀបចំបែបថ្មីនៃឯកសារបណ្តុះបណ្តាលពីចំងាយ

គណៈកម្មការបច្ចេកទេស អស់រយៈពេល ១៥ ថ្ងៃ បានទទួលការបំប៉នគរុកោសល្យពីសំណាក់អ្នកជំនាញការម្នាក់របស់អង្គការ យូណេស្កូ គឺ លោក ហ្សាក់ ឌុយរីយ៉ូ ។ ការទទួលបានចំនេះដឹងថ្មីនេះនាំអោយយើងជាប់ចិត្តទៅលើវិធីសាស្ត្រថ្មី ហើយសំរេចយកវិធីនេះជាគោលគំនិត ។ វិធីសាស្ត្រថ្មីនេះបង្ហាញយើងអោយដឹងថា គ្រប់ការបណ្តុះបណ្តាលត្រូវផ្តល់ដល់អ្នករៀននូវចំនេះចេះភ្ជាប់ពុទ្ធិទទួលបានទៅនឹងចំនេះធ្វើ គឺសមត្ថភាពចេះបង្រៀនសិស្សមានប្រសិទ្ធិភាព បើសិនជាគ្រូយើងខិតខំយកចិត្តទុកដាក់ប្រតិបត្តិតាមការណែនាំផ្តល់អោយតាមរយៈផ្នែកសំរាប់គ្រូ និងផ្នែកសំរាប់បង្រៀនសិស្សកំនត់ក្នុងឯកសារ ។

លំហាត់ និងកិច្ចការទាំងឡាយដែលស្របទៅនឹងខ្លឹមសារនៃផ្នែកទាំងពីរ សំដៅ :

- បញ្ជាក់ថាតើគ្រូយើងម្ចាស់ការបានលើមុខវិជ្ជាដែលត្រូវបង្រៀននោះដែររឺទេ ?
- ពិនិត្យមើលថាតើគ្រូយើងមានការស្តាប់បាន យល់បានត្រឹមត្រូវរឺទេចំពោះការណែនាំគរុកោសល្យ និងវិធីដឹកនាំមេរៀននីមួយៗ ។

ជាទីបញ្ចប់ ការវាយតំលៃរកភាគរយលើលទ្ធផលសំរេចរបស់សិស្សក្រោយពីចប់មេរៀននីមួយៗ ។

**ដោយ យ៉ង់ ធី**

# សារៈសំខាន់នៃអំនាន

ក្នុងចំណោមសមត្ថភាពមូលដ្ឋានបួន ក្នុងការសិក្សាភាសាខ្មែរ នៅបឋមសិក្សា គឺសមត្ថភាពស្តាប់ និយាយ អាន និងសរសេរ សមត្ថភាពអាន មានសារៈសំខាន់បំផុត តាំងពីបឋមសិក្សា រហូតដល់ឧត្តមសិក្សា ។ ខ្វះបំនិនប្រសប់ក្នុងអំនាន សិស្សានុសិស្សពុំមានលទ្ធភាពសិក្សាមុខវិជ្ជាផ្សេងៗទៀតបានឡើយ ។ ក្នុងស្ថានភាពបច្ចុប្បន្ននៅកម្ពុជា ពិសេសនៅតាមជនបទ ដោយកង្វះខាតសៀវភៅ ឯកសារ និងអត្ថបទផ្សេងៗគ្រប់ប្រភេទ ប្រជាជនទូទៅ ហាក់មិនចាប់អារម្មណ៍ក្នុងការអានឡើយ ។ បើគេចង់ដឹងពត៌មានផ្សេងៗ គេតែងតែសាកសួរគ្នាទៅវិញទៅមក រឺនិយាយរៀបរាប់ប្រាប់គ្នា ដោយមិនខិតខំស្វែងយល់តាមរយៈអំនានឡើយ ។ តែទោះស្ថិតក្នុងស្ថានភាពបែបនេះក្តី ចំពោះយើង អំនានមានតួនាទីយ៉ាងធំធេង មិនអាចខ្វះបានឡើយ ។ អំនានប្រៀបបាននឹងចំណីរបស់ខួរក្បាល ខ្វះការអាន ខួរក្បាល គ្មានការលូតលាស់ ។

ដើម្បីបញ្ជាក់បញ្ហានោះ យើងសាកល្បងលើកឡើងពីគោលបំនងសំខាន់ៗនៃអំនាន ដូចខាងក្រោមនេះ ៖

## ១. ចំពោះសិស្សានុសិស្ស និងគ្រូបង្រៀន

### ១.១. អំនានផ្តល់ពុទ្ធិគ្រប់យ៉ាង

- អំនានជាមូលដ្ឋាននៃការរៀន និងបង្រៀន ។ គ្មានសមត្ថភាពអាន គឺគ្មានសមត្ថភាពរៀន និងបង្រៀន ។ ដូចនេះអំនាន គឺជាមុខវិជ្ជាឧបករណ៍ ដែលអាចអោយសិស្សានុសិស្សឈានទៅសិក្សាមុខវិជ្ជាផ្សេងៗបាន ព្រមជាមួយនេះ អំនាន គឺជាមធ្យោបាយសំរាប់គ្រូបង្រៀន ធ្វើការស្រាវជ្រាវចំនេះដឹងយកទៅបង្រៀនសិស្សផងដែរ ។

អំនាន ជាមធ្យោបាយយ៉ាងប្រសើរ សំរាប់ការសិក្សាភាសា ៖

អោយសិស្សចេះបន្ទឹស្សូរ ញែកស្សូរ ស្រះ ព្យញ្ជនៈ

. អោយសិស្សចេះអានអក្សរ អានពាក្យ ( ឯកព្យាង្គ ពហុព្យាង្គ ) ត្រឹមត្រូវតាមសូរដែលត្រូវអាន ។

. អោយសិស្សចេះអានអត្ថបទ អានរឿង ដោយមានបែបបទត្រឹមត្រូវ (Lecture expressive)

. អោយសិស្សចេះអានស្ទាត់ អានឮ អានឃ្លាសួរ អានឃ្លាឧទាន ! ។ល។

. អោយសិស្សយល់ន័យអត្ថបទ យល់ពាក្យ ស្គាល់ពាក្យ ន័យដូច សូរដូច ពាក្យពហុន័យ សន្ទានពាក្យ ។ល។

. ហ្វឹកហ្វឺនសិស្សអោយនិយាយបានត្រឹមត្រូវ តាមរយៈលំហាត់ភាសា និងពាក្យសព្ទ ដើម្បីឈានទៅធ្វើតែងសេចក្តី ។ល។

អំនានអាចអោយសិស្សយល់ដឹងពត៌មាន និងព្រឹត្តិការណ៍ផ្សេងៗទាំងក្នុង និងក្រៅសាលារៀន ។ នៅក្នុងជីវភាព អំនានអាចអោយសិស្សយល់ដឹងពត៌មាន និងព្រឹត្តិការណ៍ផ្សេងៗ ទាំងក្នុង និងក្រៅប្រទេស តាមរយៈការអានព្រឹត្តិបត្រ រឺសារពត៌មាន ។

*ឧទាហរណ៍ :* ក្នុងសាលារៀន អំនានអាចអោយសិស្សស្វែងយល់បានពីបទបញ្ជាផ្ទៃក្នុងរបស់សាលា សេចក្តីប្រកាសផ្សេងៗ ដែលទាក់ទងដល់ការសិក្សានិងវិន័យរបស់សាលារៀន ។ល។

- អំណានអាចអោយនិស្សិត និងជាពិសេស គ្រូបង្រៀនធ្វើការស្រាវជ្រាវ និងស្វែងយល់មុខវិជ្ជាផ្សេងៗទៀត ដែលពាក់ព័ន្ធដល់ការសិក្សា និងការបង្រៀនរបស់គេ ។
- អំណានអាចអោយសិស្ស និស្សិត គ្រូបង្រៀន ស្វែងយល់ពីស្នាដៃអក្សរសិល្ប៍គ្រប់ប្រភេទ ។

### ១.២. អំណានផ្តល់ចំណេះធ្វើ រឺ បំនិនប្រសប់ដល់សិស្ស

តាមរយៈអំណានអត្ថបទផ្សេងៗ សិស្សានុសិស្សអាចត្រិះរិះពិចារណា ថ្លឹងថ្លែង វាយតំលៃទៅលើព្រឹត្តិការណ៍ រឺតួអង្គ ដើម្បីយកចំនេះដឹងទៅអនុវត្តក្នុងការរស់នៅប្រចាំថ្ងៃ ។ ចំណេះដឹងដែលទទួលបានពីអំណានអាចទុកជាបទពិសោធសំរាប់ជីវិតម្នាក់ៗ ។ បើខ្វះបំនិនប្រសប់នេះ អំណានមិនទាន់មានន័យគ្រប់គ្រាន់ឡើយ ។

### ១.៣. អំណានរួមចំនែកក្នុងការអប់រំផ្លូវចិត្ត

គ្រប់អត្ថបទអំណាន សុទ្ធតែបង្កប់ទៅដោយខ្លឹមសារអប់រំចិត្តគំនិតរបស់មនុស្ស ទៅតាមទំនោររបស់អ្នកនិពន្ធ ។

តាមរយៈចំនេះដឹង និងចំនេះធ្វើដែលទទួលបានខាងលើ សិស្សានុសិស្សនឹងអាចដកស្រង់បាននូវបទពិសោធល្អៗ សំរាប់យកទៅអនុវត្ត ។ ពេលនោះ គេនឹងសំរេចចិត្តជ្រើសរើសយកជំហរមួយ ដើម្បីលើកកំពស់គុណភាពផ្លូវចិត្តគំនិតរបស់គេ ដើម្បីកែប្រែពួកគេអោយទៅជាពលរដ្ឋល្អទៅអនាគត ។នេះគឺជាតំលៃអប់រំដែលបង្កប់នៅក្នុងអត្ថបទអំណាន ។

## ២. ចំពោះប្រជាពលរដ្ឋទូទៅ

អំណាន មានតួនាទីយ៉ាងធំធេងក្នុងការរួមចំនែកជានាសុវត្ថិភាពក្នុងការរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប ។ មនុស្សមានសមត្ថភាពអាន គឺមានភាពម្ចាស់ការក្នុងការរស់នៅ ៖

- គេអាចស្វែងយល់បាន ពីពត៌មានដោយខ្លួនគេផ្ទាល់ ដោយមិនចាំបាច់ពឹងពាក់អ្នកដទៃ អោយជួយប្រាប់ រឺអានអោយស្តាប់ ។

*ឧទាហរណ៍ :* ពេលឃើញប័ណ្ណប្រកាសបិទតាមផ្លូវ គេអានបាន ហើយយល់ខ្លឹមសារ ។

- ពេលគេចង់ដឹងខ្លឹមសាររឿងព្រេង គេយកសៀវភៅមកអាន មិនចាំបាច់សួរគេអោយនិយាយប្រាប់ ។
- គេអាចធានាសុវត្ថិភាពក្នុងជីវិតបាន ពោលគឺចៀសវាងគ្រោះថ្នាក់ផ្សេងៗបាន នៅក្នុងការរស់នៅ ៖

*ឧទាហរណ៍ :*

. ចេះអានសំបុត្រប្រើប្រាស់ថ្នាំពេទ្យ នាំអោយគេចេះប្រើប្រាស់ថ្នាំពេទ្យ ស្គាល់គ្រោះថ្នាក់បណ្តាលមកពីថ្នាំពេទ្យ ។ល។

. ចេះអានសំបុត្រប្រើប្រាស់សំភារៈ រឺឧបករណ៍ គ្រឿងអេឡិចត្រូនិច អាចសំរួលការប្រើប្រាស់ឧបករណ៍ទាំងនោះបាន ព្រមទាំងចេះរបៀបថែរក្សាបានយូរផងដែរ ។

ចេះអានសេចក្តីណែនាំ សេចក្តីប្រកាស សេចក្តីជូនដំណឹងរបស់រដ្ឋ របស់រោងចក្រ សហគ្រាស នាំអោយចៀសវាងបាន នូវការមិនគោរពវិន័យ ។ ល ។

- គេអាចចៀសវាងបាននូវការបោកប្រាស់ កិបកេងប្រវ័ញ្ច បណ្តាលមកពីទុច្ចរិត ។

*ឧទាហរណ៍ :* ពេលធ្វើលិខិតចុះកិច្ចសន្យាខ្ចីប្រាក់ កិច្ចសន្យាបញ្ចាំរបស់របរផ្សេងៗ ។ ល ។ បើមិនចេះអាន គេអាចចុះហត្ថលេខា រឺផ្តិតមេដៃលើលិខិតក្លែងក្លាយ ខុសពីការពិត ពេលនោះនឹងជួបគ្រោះថ្នាក់មិនខាន ។

- គេអាចមានទស្សនៈទូលាយ យល់ពីការពិតក្នុងជីវិត យល់ពីព្រឹត្តិការណ៍ផ្សេងៗតាមរយៈអំនានសារពត៌មាន រឺ ព្រឹត្តិបត្រទស្សនាវដ្តី សេចក្តីប្រកាសជាសាធារណៈរបស់រាជរដ្ឋាភិបាល ។ ល ។

ក្នុងឋានៈជាពលរដ្ឋថ្ងៃថ្នូរម្នាក់ ចេះអាន គឺមានលទ្ធភាពសិក្សា ស្វែងយល់ពីច្បាប់ទំលាប់សំរាប់ប្រទេស ទំនៀមទំលាប់ប្រពៃណីជាតិ ច្បាប់ចរាចរណ៍ ។ ល ។

- ចេះអាន អាចពង្រីកបាននូវសិទ្ធិប្រជាធិបតេយ្យរបស់ខ្លួន សិទ្ធិក្នុងការរស់នៅ សិទ្ធិក្នុងការជ្រើសរើស សិទ្ធិក្នុងការបោះឆ្នោត ។ ល ។

*ឧទាហរណ៍ :* ក្នុងការបោះឆ្នោត អំនានអាចអោយគេស្វែងយល់ពីបេក្ខភាព ចំនុចខ្លាំង ចំនុចខ្សោយរបស់បេក្ខជននីមួយៗ ។ បន្ទាប់មក គេធ្វើការជ្រើសរើសដោយខ្លួនគេផ្ទាល់ បេក្ខជនណាមួយដែលគេយល់ថា ល្អ ហើយពេញចិត្ត ។

- ចេះអានសំរួលការធ្វើដំនើរស្នាក់នៅរបស់យើង ទៅកន្លែងណា ដែលយើងមិនធ្លាប់ស្គាល់

*ឧទាហរណ៍ :* ពេលធ្វើដំនើរតាមយន្តហោះ បើមិនចេះអាន យើងវង្វេងក្នុងព្រលាន ។ ពេលធ្វើដំនើរតាមផ្លូវយើងចំនាំផ្លូវមិនបាន ។

- ចេះអាន នាំអោយមនុស្សមានសីលធម៌ មានសុជីវធម៌ ចេះគោរពគ្នាទៅវិញទៅមក... ។

## ៣. ចំពោះគ្រូបង្រៀន និង អ្នកស្រាវជ្រាវ

អំនានផ្តល់លទ្ធភាពអោយគេស្វែងយល់បាននូវរាល់ស្នាដៃល្អៗរបស់អ្នកប្រាជ្ញ អ្នកកវី អ្នកនិពន្ធជំនាន់មុន ទាំងផ្នែកអក្សរសាស្ត្រ ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ បច្ចេកទេស រឺ បច្ចេកវិទ្យាថ្មីៗ ។ ចំពោះអ្នកស្រាវជ្រាវ អានកាន់តែច្រើន កាន់តែរកឃើញច្រើន បទពិសោធក៏កាន់តែទទួលបានច្រើន ឯគ្រូបង្រៀនក៏ដូច្នេះដែរ ។ បើមិនអានច្រើន ការបង្រៀនក៏មិនបានល្អដែរ ។

ការរៀបរាប់ខាងលើបង្ហាញអោយឃើញថា អំនានជាការចាំបាច់ប្រចាំជីវិតមនុស្ស ខ្វះអំនានខួរក្បាល នឹងខ្វះចំណីអាហារទ្រទ្រង់ការលូតលាស់ ។ តើនេះបណ្តាលមកពីអ្វី ? **ហេតុអ្វីបានជាត្រូវអាន ?**

ជាធម្មជាតិ តំរូវការរបស់មនុស្សមានពីរ គឺ :

- តំរូវការជាសំភារៈ ដូចជា : ហូបចុក ស្លៀកពាក់ និងទីស្នាក់នៅ
- តំរូវការផ្នែកស្មារតី : គឺជាចំនីរបស់ខួរក្បាល ដើម្បីធានាការលូតលាស់ល្អសំរាប់សុវត្ថិភាព

យ៉ាងណាមិញ អំណានអាចចាត់ទុកជាចំណីម្យ៉ាងរបស់ខួរក្បាល ដើម្បីធានាការលូតលាស់លើគ្រប់ផ្នែក ។ ដូចនេះ មនុស្សគ្រប់រូប ត្រូវតែអានដើម្បី ៖

## បំបាត់ការអផ្សុក - បង្កើតការសប្បាយរីករាយ

ជំនក់ចិត្តក្នុងអំណាននាំអោយមនុស្សសប្បាយរីករាយនឹងអានគ្រប់អត្ថបទ ។ ក្នុងអំណាន តែងមានរឿងរ៉ាវគ្រប់បែបយ៉ាង : រឿងអស្ចារ្យ រឿងកំសត់ រឿងកំប្លែង រឿងស្នេហាប្រាត់ប្រាស់ រឿងវិទ្យាសាស្ត្រ ។ ល ។ ដែលសុទ្ធសឹងជាបាតុភូត ដែលតែងទាក់ទងដល់ជីវភាពរបស់មនុស្ស រឺជារឿងដែលមនុស្សអាចនឹងជួបប្រទះ ។ គឺរឿងទាំងនោះហើយ ដែលធ្វើអោយមនុស្សអណ្ដែតអណ្ដូង ភ័យ ព្រួយ សប្បាយរីករាយ រំភើប ញាប់ញ័រ ។ តែទោះស្ថិតក្នុងសភាពបែបណា ក៏រឿងទាំងនេះ តែងបំផុសអារម្មណ៍ស្មូគ្រស្មាញរបស់អ្នកអាន ហើយភាគច្រើន ធ្វើអោយមនុស្សសប្បាយរីករាយ ។

## ទុកជាមធ្យោបាយផ្ដល់ពុទ្ធិ ទទួលពុទ្ធិ និងស្រាវជ្រាវពុទ្ធិ

ដើម្បីផ្ដល់ពុទ្ធិគ្រប់ប្រភេទដល់អ្នកដទៃ គេអាចបញ្ចូលពុទ្ធិទាំងនោះ នៅក្នុងអត្ថបទអំណាន ។ ឯអ្នកទទួលពុទ្ធិវិញ ក៏ចាំបាច់ត្រូវការអានអត្ថបទផ្សេងៗដែរ ។ អត្ថបទគ្រប់ប្រភេទ ជាប្រភពចំនេះដឹងគ្រប់បែបយ៉ាង ។ ចំពោះអ្នកស្រាវជ្រាវ ក៏ត្រូវការអំណានដោយខានមិនបានដែរ ។

*ឧទាហរណ៍* : ចង់ដឹងពត៌មានវិទ្យាសាស្ត្រ ត្រូវអានអត្ថបទ ដែលនិយាយពីវិទ្យាសាស្ត្រ ។

- ចង់បានចំនេះដឹងផ្នែកនយោបាយ សេដ្ឋកិច្ច ត្រូវមានសៀវភៅដែលរៀបរាប់ពីនយោបាយ និយាយពីសេដ្ឋកិច្ច ។
- ចង់ដឹងព្រឹត្តិការណ៍ រឺការវិវត្តរបស់សង្គមពីអតីតកាល ត្រូវអានឯកសារ ប្រវត្តិសាស្ត្រ ។

ដូចនេះហើយ ទើបគេពោលថា អំណានជាប្រភពផ្សព្វផ្សាយពុទ្ធិផង ទទួលពុទ្ធិផង ស្រាវជ្រាវពុទ្ធិផង ។

## បង្កើតទំនាក់ទំនងផ្នែកមនោសញ្ចេតនា

ក្នុងទំនាក់ទំនងមនោសញ្ចេតនារវាងមនុស្ស និងមនុស្ស អំណានក៏ដើរតួនាទីយ៉ាងសំខាន់ណាស់ដែរ ។

*ឧទាហរណ៍* : អំណានសំបុត្រអាចអោយយើងដឹងពីមនោសញ្ចេតនា អ្នកសរសេរចំពោះខ្លួនយើង ៖

- មនោសញ្ចេតនាឪពុក និង កូន
- មនោសញ្ចេតនា ប្ដី ប្រពន្ធ
- មនោសញ្ចេតនា រវាងមិត្តភក្តិ - គូសង្សារ ។ ល ។

ក្នុងការសិក្សាស្នាដៃអក្សរសិល្ប៍ អំណានអាចអោយអ្នកសិក្សាស្វែងយល់ពីសញ្ចេតនា ពីបំនងប្រាថ្នា ពីទំនោរ និងចំនង់ចំនូលចិត្តរបស់អ្នកនិពន្ធ ។

យ៉ាងណាមិញ អំណានក៏ជាចំណីអាហារសំរាប់បំប៉នការលូតលាស់របស់ខួរក្បាលដែរ ។ មនុស្សត្រូវការចំណីអាហារសំរាប់ទ្រទ្រង់ជីវិត និងការលូតលាស់ ។ ប៉ុន្តែ ជាក់ស្ដែងបច្ចុប្បន្ននៅកម្ពុជា ទាំងសិស្សានុសិស្ស ទាំងប្រជាពលរដ្ឋទូទៅ មិនទាន់ចាប់អារម្មណ៍ខ្ពស់ក្នុងអំណាននៅឡើយទេ ដូចនេះ ៖

# តើយើងត្រូវធ្វើដូចម្តេចដើម្បីលើកទឹកចិត្តកុមារអោយចង់អាន និង មានទំលាប់អានសៀវភៅ ?

ជាធម្មតា កុមារតូចៗចូលចិត្តស្តាប់ជាងអាន ប៉ុន្តែបើគ្រូចេះលើកទឹកចិត្ត សិស្សអាចចូលចិត្តអានជាងស្តាប់ ។ កត្តាសំខាន់ៗសំរាប់លើកទឹកចិត្តអោយសិស្សចង់អាន មានដូចខាងក្រោម ៖

*កត្តាណែនាំរបស់គ្រូ ៖*

ត្រូវបង្កបរិយាកាសរីករាយ ដែលអាចអោយសិស្សអានបាន
( គ្មានការស្តីបន្ទោស បង្ខិតបង្ខំ គំរាមកំហែង )

ទីកន្លែងសមរម្យ មានពន្លឺគ្រប់គ្រាន់ ពេលវេលាអនុគ្រោះ ស្ងប់ស្ងាត់

បង្កើតការប្រលងប្រនាំងក្នុងអំនាន បង្កើតល្បែងភាសា

បំផុសរឿងនិទានប្លែកៗ រួចអោយសិស្សអានបន្ត ...

លើកទឹកចិត្តសិស្ស ដែលអានបានល្អ រឺអានបានអត្ថបទច្រើន

មិនបន្ទុះបង្អាប់សិស្សអានខុស

ជ្រើសរើសអត្ថបទ រឺសៀវភៅដែលមានអក្សរច្បាស់ៗ ងាយអាន មានរូបភាពល្អៗ និងមានខ្លឹមសារស្របតាមវ័យរបស់កុមារ ។

*កត្តាខ្លឹមសារអត្ថបទ រឺ សៀវភៅ ៖*

អត្ថបទ រឺ សៀវភៅដែលមានខ្លឹមសារ និង អត្ថន័យមិនសមស្របនឹងវ័យ រឺ កំរិតយល់ដឹងរបស់កុមារ ធ្វើអោយកុមារធុញទ្រាន់មិនចង់អាន ។ អត្ថបទពិបាកពេក រឺ ងាយពេក មិនធ្វើអោយកុមារចាប់អារម្មណ៍ឡើយ ។ ដូចនេះ សៀវភៅ រឺអត្ថបទដែលដាក់អោយសិស្សអានត្រូវ ៖

- មានខ្លឹមសារអប់រំល្អ ពាក្យសំដី ឃ្លាប្រយោគងាយយល់ និងរំលេចដោយរូបភាពល្អៗផង ។
- មានខ្លឹមសារស្របតាមចំនូលចិត្តរបស់កុមារតាមវ័យ ដើម្បីអោយកុមារមានអារម្មណ៍ចង់ដឹង ចង់តាមដានសាច់រឿង ។ អត្ថបទពិបាកពេក នាំអោយសិស្សអស់សង្ឃឹម ធុញទ្រាន់ក្នុងការអាន ។
- មានការទាក់ទាញសិស្ស អោយរំភើប សប្បាយរីករាយ ចង់ដើរតួក្នុងសាច់រឿង ។
- មានលក្ខណៈបង្កើតស្ថានភាពបញ្ហា ដើម្បីអោយសិស្សចូលរួមគិត និងដោះស្រាយ រឺចង់ដឹងដំនោះស្រាយរបស់អត្ថបទ ។
- មានខ្លឹមសារសមស្របនឹងស្ថានភាពជាក់ស្តែង ក្នុងការរស់នៅរបស់កុមារ ។

ការលើកទឹកចិត្តអោយកុមារចង់អានជាការសំខាន់ ដែលត្រូវតែយកចិត្តទុកដាក់ក៏ពិតមែនហើយ តែទន្ទឹម

នេះ ក៏ត្រូវបង្កលទ្ធភាពអោយកុមារអានបានផងដែរ ។

*តើយើងត្រូវចេះអ្វីខ្លះ ដើម្បីអានបាន ?*

ដើម្បីអានបាន យើងត្រូវមានបំនិនប្រសប់ច្រើនយ៉ាង ៖

- ក្នុងសរសេរអក្សរខ្មែរ គេសរសេរពីឆ្វេងទៅស្តាំ ដូចនេះ ពេលអានត្រូវអានពីឆ្វេងទៅស្តាំដែរ ។ផ្ទុយពីអក្សរចិន ដែលសរសេរពីលើចុះក្រោម ដែលត្រូវអានពីលើចុះក្រោមដែរ ។
- ត្រូវស្គាល់អក្ខរក្រមក្នុងភាសាខ្មែរ
  . ស្គាល់សញ្ញាតួអក្សរ : គឺ ស្រះ និង ព្យញ្ជនៈ
  . ស្គាល់សូរ និង ចេះញែកសូរអក្សរ : សូរស្រះ - ព្យញ្ជនៈ ( ឃោសៈ - អឃោសៈ )
  . ចេះប្រកបពាក្យ ចេះអក្សរផ្ចិតផ្ចង់
- ត្រូវចេះអានពាក្យ ( ពាក្យឯកព្យាង្គ - ពាក្យពហុព្យាង្គ - ពាក្យមានតួអក្សរមិនអាន )
- ត្រូវចេះអានឃ្លា - អានអត្ថបទទាំងមូល ( អានស្ងាត់ - អានឮ - អានមានបែបបទ )
- ត្រូវយល់ដឹងពីផ្នែកផ្សេងៗនៃសៀវភៅដូចជា ៖
  . ទីតាំងទំព័រដំបូង - ទំព័រចុងក្រោយ
  . ចេះមើលចំនងជើងសៀវភៅ រឺ អត្ថបទ
  . ចេះមើលមាតិការឿង
  . ចេះប្រើប្រាស់អត្ថបទយោង - សទ្ទានុក្រម - ទំព័រកែតំរូវ . . .
- ត្រូវមានសមត្ថភាពទស្សន៍ទាយទុកមុន នូវដំណើររឿងក្នុងអត្ថបទ
  . មានសមត្ថភាពយល់អត្ថបទដែលបានអាន
  . មានសមត្ថភាពវាយតំលៃបត្តិលក្ខណៈរបស់តួអង្គ
  . យល់ដឹងពីប្រធានផ្សេងៗ របស់អត្ថបទអក្សរសិល្ប៍
- ត្រូវយល់អត្ថន័យ និង ខ្លឹមសាររបស់អត្ថបទដែលបានអាន :
  . យល់ពាក្យពិបាកៗ - យល់ពាក្យដែលប្រើប្រាស់ក្នុងទិសេចក្តីផ្សេងៗគ្នា
  . យល់ខ្លឹមសារទាំងមូល ដោយចេះទាញជាខ្លឹមសារអប់រំរបស់អត្ថបទ ។

**ដោយ លោក ណាត ប៊ុនរឿន**

**និង**

**លោក លីម ចេង**

# ការត្រិះរិះពិចារណាពីមេរៀន
# វិទ្យាសាស្ត្រអនុវត្ត

## មេរៀន ស្តីអំពី « ខ្យល់ »

មនុស្សយើង ពេលធំឡើងដឹងក្តី តែងតែយល់គ្រប់ៗគ្នា ពីសារៈសំខាន់នៃខ្យល់សំរាប់ដកដង្ហើម ដែលទ្រទ្រង់ជីវិតរបស់គេ ។

ពាក្យថា « ខ្យល់ » នេះ គឺជាពាក្យសាមញ្ញ ដែលចង់និយាយពីខ្យល់ដែលមាននៅក្នុងបរិយាកាស ។ ខ្យល់នៅក្នុងបរិយាកាស គឺជាល្បាយឧស្ម័នជាច្រើន ក្នុងសមាមាត្រខុសៗគ្នា ដែលក្នុងនោះ ឧស្ម័នអុកស៊ីសែន និងអាសូតមានសមាមាត្រច្រើនជាងគេ ។

ដូចនេះ ការបង្រៀនអោយសិស្សនៅបឋមសិក្សាយល់ដឹងពី « ខ្យល់ » គឺមានកំរិតខុសៗគ្នា ពីថ្នាក់ទាបទៅថ្នាក់ខ្ពស់ (ពីថ្នាក់ទី ២ ដល់ថ្នាក់ទី ៤) ពោលគឺទៅតាមកំរិតវិវឌ្ឍន៍នៃបញ្ញារបស់សិស្ស បានន័យថា ពីការយល់ដឹងស្រាល ទៅការយល់ដឹងជ្រៅជ្រះបន្តិចម្តងៗ ។

យើងដឹងហើយថា នៅបឋមសិក្សា ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រអនុវត្ត គឺត្រូវឈរនៅលើមូលដ្ឋានសង្កេតអនុវត្តជាក់ស្តែង ។

ខ្យល់ជាវត្ថុជាក់ស្តែង គឺមានពិតប្រាកដមែន តែមានលក្ខណៈម៉្យាង គឺត្រង់យើងមើលពុំឃើញ ប៉ុន្តែវាងាយនឹងធ្វើពិសោធ ។ វាមាននៅពាសពេញក្នុងបរិយាកាសជុំវិញខ្លួនយើង ។

ដូចនេះ ក្រៅពីឧទាហរណ៍ក្នុងសៀវភៅវិទ្យាសាស្ត្រអនុវត្ត ដែលអនុញ្ញាតអោយបោះពុម្ពដោយក្រសួងអប់រំ យុវជន និង កីឡា ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំនេះទូទៅ លោកគ្រូ-អ្នកគ្រូ អាចបន្ថែមជាសំនួរ រឺឧទាហរណ៍ រឺការអនុវត្តន៍ផ្សេងៗទៀតជាច្រើន ៖

- អោយសិស្សបិទមាត់អោយជិត ហើយបំប៉ោងខ្យល់នៅក្នុងថ្ពាល់ រួចយកប្រាមដៃចុចសង្កត់ថ្ពាល់ទាំងសងខាង អោយធ្លាយខ្យល់ចេញតាមមាត់ ។
- អោយសិស្សយកប៉េងប៉ោងមកផ្លុំ (បើគ្មានប៉េងប៉ោង អាចយកថង់ប្លាស្ទិចផ្លុំក៏បាន ។ល។...)
- អោយសិស្សយកកង្ហារធ្វើពីក្រដាស រឺ ស្លឹកត្នោត មកដាក់អោយចំកន្លែងខ្យល់បក់ (រឺផ្លុំ ក្នុងករណីគ្មានខ្យល់បក់) ។
- អោយសិស្សយក ៖ ទោចក្រយានយន្ត និងស្នប់មកធ្វើពិសោធន៍ ។
- អោយសិស្សបង្ហោះខ្លែង (បញ្ជាក់ថា ខ្យល់សំរួលក្នុងការហោះហើរ)
- អោយសិស្សបោះពោងទៅក្នុងទឹក (បញ្ជាក់ថា ខ្យល់សំរួលក្នុងការអណ្តែតទឹក) ។

ចំពោះការពិសោធន៍ដោយអោយសិស្សទៅខ្ទប់ច្រមុះ មាត់ មិត្តរបស់គេនោះ លោកគ្រូ-អ្នកគ្រូ គួរមានការហាមប្រាមជាមុន កុំអោយសិស្សលេងផ្ដេសផ្ដាស ហួសព្រំដែន (ដូចជា សិស្សខ្លះអាងកំលាំងខ្លាំងជាងគេ ខ្ទប់ច្រមុះ មាត់ មិត្តរបស់គេយូរពេក អាចបណ្ដាលអោយមានជំលោះ រឺបញ្ហាផ្សេងៗដល់មាតាបិតា រឺ អ្នកអាណាព្យាបាលសិស្សនោះ) ។

ចំពោះពិសោធន៍ស្ដីពីសារៈសំខាន់នៃខ្យល់ដកដង្ហើមទៅលើជីវិតសត្វ រឺ រុក្ខជាតិ ត្រូវធ្វើដោយហ្មត់ចត់ ព្រោះជៀសវាងកត្តាដទៃទៀត ដែលមានឥទ្ធិពលដល់ជីវិតសត្វ និង រុក្ខជាតិ (ការពិសោធន៍វិទ្យាសាស្ត្រ មិនមែនជាការបន្លំភ្នែក រឺបាំហ៊ីទេ) ដូចជា ដាក់មេអំបៅ រឺ ដាក់កូនរុក្ខជាតិបៃតងក្នុងកែវដបគ្របអោយជិត គួរកុំយកកែវដបធំពេក គឺអោយល្មមនឹងសត្វ រឺ រុក្ខជាតិនោះ ជៀសវាងការចំនាយពេលវេលាយូរក្នុងការពិសោធន៍ផង និងម្យ៉ាងទៀត ជៀសវាងកត្តាដទៃទៀត ដូចជាសីតុណ្ហភាពជាដើម ដែលមានឥទ្ធិពលដល់ជីវិតសត្វ និងរុក្ខជាតិផង (ដបកែវបិទជិត បើដាក់ចំពន្លឺថ្ងៃ ខ្យល់នៅក្នុងនោះ និងឡើងក្ដៅដោយបាតុភូត « ផលនៃតំរបថ្នា » « effet de serre >> ឯរុក្ខជាតិបៃតងវិញ បើបិះពន្លឺថ្ងៃ នឹងមានបាតុភូតរស្មីសំយោគ ហើយបញ្ចេញឧស្ម័នអុកស៊ីសែន ។ល។...) ។

សរុបសេចក្ដីមក គួរយកពិសោធន៍ណាងាយៗ មកធ្វើអោយសិស្សមើល ជៀសវាងការដែលសិស្សសួរដេញដោល ហើយដែលគ្រូពុំអាចឆ្លើយបាន និងយកឧបករណ៍ណាងាយៗ ដែលសំបូរនៅក្នុងប្រទេសយើង (ចំពោះឧទាហរណ៍ មនុស្សកង្កែបនៅប្រទេសយើង គេកំរនឹងឃើញផ្ទាល់ភ្នែកណាស់ ច្រើនតែឃើញក្នុងភាពយន្ត រឺវីដេអូតែប៉ុណ្ណោះ ) ។



ខ្យល់មាននៅជុំវិញខ្លួនយើង ។ បិទមាត់ហើយបំបៅងខ្យល់ក្នុងថ្ពាល់ ។ យកម្រាមដៃចុចថ្ពាល់ ដើម្បីអោយខ្យល់ប្រាលចេញតាមមាត់

ខ្លែងហោះដោយសារខ្យល់

ពោងអណ្ដែតទឹកដោយសារខ្យល់នៅពីក្នុង ។

**លោក យ៉ង់ យ៉ាណូ**

# គរុកោសល្យនៃសកម្មភាព
# Pédagogie des activités

## ១- សកម្មភាពសិស្សជាមូលដ្ឋាននៃការបង្រៀនរបស់គ្រូ :

ក- នៅលើសកលលោក ចុងសតវត្សទី១៩ គេបានកំនត់ថា : គោលបំនងជាអាទិភាព និងគ្រប់គ្រាន់ក្នុងការបង្រៀនសិស្ស គឺអាន (lire) សរសេរ (écrire) និងរាប់ (compter) ។ សកម្មភាពគ្រូ គឺជាកត្តាកំនត់ ចំពោះលទ្ធផលសិក្សារបស់សិស្ស ។ គ្រូជាអ្នកពន្យល់យ៉ាងក្បោះក្បាយ សិស្សជាអ្នកចាំតែទទួលយកពីគ្រូ ។

ប៉ុន្តែ បច្ចុប្បន្នកាលនេះ បេសកកម្មរបស់សាលារៀនបឋមសិក្សា ត្រូវបានផ្លាស់ប្តូរ ពោលគឺធ្វើអោយសិស្សរីកលូតលាស់ជាប្រចាំ នូវចំនេះដឹង (savoir) ចំនេះធ្វើ (savoir-faire) និងការអប់រំ (savoir-être) ។ បណ្ឌិតវិទូ និងអ្នកអប់រំទាំងឡាយយល់ថា គឺសិស្សខ្លួនឯងដែលត្រូវកសាងចំនេះដឹងរបស់ខ្លួន តាមរយៈសកម្មភាពខ្លួនឯង (C'est l'enfant lui-même qui construi son savoir par son activité) ។ គ្រូដែលមានសមត្ថភាព (compétence) ពុំមែនជាគ្រូដែលពូកែផ្ទេរចំនេះដឹងដោយសូត្រអោយសិស្សនោះទេ តែផ្ទុយទៅវិញ គឺជាគ្រូដែលមានបំនិនប្រសប់ក្នុងការដឹកនាំសិស្សអោយចេះធ្វើសកម្មភាព ដើម្បីកសាងពុទ្ធិរបស់ខ្លួនដោយខ្លួនឯង ។ គ្រូគឺជាអ្នកណែនាំ (animateur) នៃក្រុមសិស្ស ជាអ្នកជំរុញ (incitateur) នៃការស្រាវជ្រាវ ជាកាតាលីករ (catalyseur) នៃឥរិយាបថ និង វិធីសាស្ត្រ ។

- អប់រំសិស្ស គឺបង្ហាត់សិស្សអោយចេះរស់នៅ (Eduquer des enfants, c'est leur apprendre à vivre) ។

ដើម្បីបង្ហាត់សិស្សអោយចេះរស់នៅ គេត្រូវជំរុញឥន្ទ្រីយ៍របស់វាអោយលូតលាស់ ពុំមែនធ្វើអោយវាស្ពឹកនោះទេ ។

- គ្រូត្រូវធ្វើអោយសិស្សរីកលូតលាស់សកម្មភាព និងបុគ្គលិកលក្ខណៈ (activité et personnalité) ។

ដើម្បីអោយសិស្សសំរេចបាននូវការរីកលូតលាស់ខាងលើនេះ ថ្នាក់រៀនត្រូវមានបរិយាកាសទំនាក់ទំនងគ្នាល្អ និងតាមធម្មជាតិ ។

- សិស្សមានតួនាទីរកអោយឃើញនូវចំនេះដឹងថ្មី ហើយត្រូវហ្វឹកហ្វឺននឹងការស្រាវជ្រាវ បានន័យថា សិស្សហាត់រៀនសូត្រ (apprendre à apprendre) ។

- គឺជារឿងអាក្រក់មួយ កាលបើគ្រូសួរសំនួរមួយ ហើយចំលើយមានតែមួយតាមគំរូដែលគាត់បានពន្យល់ ។ ក្នុងករណី **ស្ថានភាពបិទ** នេះមានសិស្សខ្លះដែលឆ្លើយ ហើយសិស្សឯទៀតនៅស្ងៀម ដោយខ្លាចមិនហ៊ានផ្តល់ចំលើយតាមគំរូរបស់គ្រូ ដែលបានពន្យល់ រឺ ដាក់អោយ ។

- គឺជារឿងល្អប្រសើរ កាលណាសិស្សខំស្រាវជ្រាវក្នុងគំនិតដើម្បីឆ្លើយនឹងសំនួរបើក (question ouverte) ដែលមានចំលើយច្រើន ។

- គ្រូត្រូវរក្សាសិស្សអោយផ្លាស់ប្តូរយោបល់គ្នាវា ។ គេមិនត្រូវកំនត់ថា មានតែទំនាក់ទំនងគ្រូ-សិស្ស រឺ

សិស្ស-គ្រូប៉ុណ្ណោះទេ តែត្រូវមានទំនាក់ទំនងទៅមករវាងសិស្សម្នាក់-សិស្សម្នាក់ រឺសិស្សម្នាក់-សិស្សមួយក្រុម ។ គ្រូមិនត្រូវប្រកាន់អំពីសិទ្ធិអំនាចរបស់ខ្លួនពេកទេ ។ គ្រូត្រូវទុកអោយសិស្សនិយាយបញ្ជាក់ រឺ ពន្យល់ដើម្បីយើងក្តាប់បានពីគំនិតយល់ដឹងរបស់វា ហើយយើងរកវិធីជួយវាវិញ ។

១- ប្រៀបធៀបវិធីសកម្ម ( méthodes activives ) និងវិធីទទួលយក ( méthodes réceptives ) :

| | |
|---|---|
| * - សិស្សនិយាយ ៨០ % <br> - សិស្សនិយាយផង ធ្វើសកម្មភាពផង ៩០ % | * ក្នុង១ពេល : ១០ % សិស្សអាន <br> ២០ % សិស្សស្តាប់ <br> ៣០ % សិស្សឃើញ <br> ៥០ % សិស្សឃើញ និង ស្តាប់ |
| * សិស្សនិយាយ <br> * សិស្សនិយាយផង ធ្វើសកម្មភាពផង <br> * សិស្សរកឃើញចំនេះដឹង ដោយគ្រូសួរសំនួរបំផុស <br> * សិស្សហាត់អាន <br> * សិស្សដោះស្រាយលំហាត់ - ចំនោទស្ថានភាពបញ្ហា <br> * សិស្សធ្វើអន្តរសកម្ម (interaction) <br> * សិស្សធ្វើការងារសហការ (co-travail) | * សិស្សគិតតែស្តាប់គ្រូពន្យល់ <br> * សិស្សគិតតែថាតាមគេ <br> * សិស្សអានតាមគេ <br> * សិស្សសរសេរតាមគេ |

## ២- ការរៀបចំសកម្មភាពសិស្ស :

វាមានទំងន់ច្រើនយ៉ាងក្នុងការកសាងចំនេះដឹងសិស្ស ហើយគេឃើញថាទំរង់ទាំងអស់នោះ មិនសមមូលគ្នាទេ ។ គ្រូត្រូវតែជ្រើសរើសសកម្មភាពនៃយុទ្ធវិធីក្នុងការបង្រៀន ដោយប្រែប្រួលទៅតាមស្ថានភាព ( situation ) ពោលគឺប្រែប្រួលទៅតាម៖

- គោលបំនង ខ្លឹមសារ ( objectifs, contenus )
- សំភារៈទ្រទ្រង់ ( support )
- ចរិកលក្ខណៈថ្នាក់រៀន ( Caractéristiques de la clase )
- សក្តានុភាពនៃសិស្ស ( potentialités des élèves )

* ការបង្រៀនសិស្សអំពីបញ្ញត្តិ រឺ សញ្ញាណគួររៀបចំ **ការងារសិស្សជាបុគ្គល** ( travail individuel )

* ការបង្រៀនសិស្សអំពីរូបមន្ត ( formule ) ចំនេះធ្វើ ( savoir-faire ) ដោះស្រាយចំនោទ ល្បែងគណិតវិទ្យា រឺស្ថានភាពបញ្ហា . . . គួររៀបចំ **សិស្សជាក្រុមតូចៗ** ដែលមានគ្នាពី ៤ ទៅ ៦ នាក់ ក្នុងមួយក្រុម ។

## ៣- ការងារក្រុមតូច ( travail en sous-groupe )

ការរៀបចំសិស្សជាក្រុមតូចៗ ត្រូវយោងទៅតាមតំរូវការ ( les besoins ) និងផលប្រយោជន៍ (les intérêts)

របស់សិស្សម្នាក់ៗ ដើម្បីអោយបានជាក្រុមដែលដូចគ្នា ( groupes homogènes ) ។ ពោលគឺ ក្រុមដែលសិស្សម្នាក់ៗមានលក្ខណៈប្រហាក់ប្រហែលគ្នា ។ ក្រុមទាំងនោះ ធ្វើសកម្មភាពប្រមៗគ្នា ហើយគ្រូត្រូវសិស្សខ្លះធ្វើសំនួមពរសួរ ដើម្បីជំរុញការងាររបស់ខ្លួន ។ គ្រូជាអ្នកជំរុញអោយញែក ( stimuler ) ដើម្បីអោយក្រុមនោះ ( relancer ) ឱណាមិច ។

*ការប្រើបច្ចេកទេសបង្រៀនរបៀបនេះ មានទំរង់ច្រើនបែប ៖*

- ការងារក្រុមតូចៗ តាមផែនការដូចៗគ្នា ដែលកំនត់ដោយគ្រូ
- ការងារក្រុមតូចៗ តាមផែនការជ្រើសរើស និងកសាងដោយសិស្ស តែស្ថិតក្នុងក្របខ័ណ្ឌគោលបំនងដែលគ្រូបានដាក់ចុះ
- ការងារក្រុមតូចៗតាមផែនការជ្រើសរើសដោយសិស្សខ្លួនឯង តែមានការយល់ព្រមពីគ្រូ ។

ក្នុងថ្នាក់រៀន ពេលអោយសិស្សធ្វើសកម្មភាពតាមក្រុមតូចៗ គួររៀបចំសិស្សតាមរបៀបខាងក្រោម ៖












# វិន័យសាលារៀន និង ការគោរព បុគ្គលិកលក្ខណៈ របស់កុមារ

ថ្នាក់រៀន គឺជាសង្គមតូចដែលមានសិស្សានុសិស្សទាំងពីរភេទ ជាសមាជិកក្រោមការដឹកនាំរបស់គ្រូបង្រៀន ទៅតាមច្បាប់ និង បទបញ្ជាផ្ទៃក្នុងរបស់សាលារៀនដែលទទួលស្គាល់ដោយក្រសួងអប់រំ ។ របៀបរៀបរយ និង វិន័យ ជាលក្ខខ័ណ្ឌចាំបាច់សំរាប់ធានាភាពរីកចំរើន និងការមានកេរ្តិ៍ឈ្មោះរបស់ថ្នាក់រៀន និង សាលារៀននិមួយៗ ។

ទន្ទឹមនឹងនេះផងដែរ សាលារៀនក៏ត្រូវមានបេសកកម្មបណ្ដុះបុគ្គលិកលក្ខណៈរបស់កុមារផងដែរ ។

តើត្រូវសហការសុខដុមយ៉ាងណាការវាងការចាំបាច់ទាំងពីរនេះ ដែលមើលទៅហាក់ដូចជាបដិបក្ខនឹងគ្នារួចជាស្រេចហើយនោះ ?

ក្នុងអតីតកាល ការអប់រំក្នុងសង្គមខ្មែរ នៅពេលដែលឪពុកម្ដាយនាំកូនប្រុសជាដំបូងទៅប្រគេនលោកគ្រូចៅអធិការវត្តតែងទូលលោកថា : « ខ្ញុំព្រះករុណា សូមទុកតែភ្នែកនឹងឆ្អឹង ក្រៅពីនោះសូមប្រគេនព្រះតេជព្រះគុណម្ចាស់ទាំងអស់ » ។

ក្នុងបទបញ្ជាផ្ទៃក្នុងសាលារៀនបឋមសិក្សាបច្ចុប្បន្ននេះ ក្នុងប្រការទី ១៧ បានសរសេរថា : « ការដាក់ទណ្ឌកម្មដល់រាងកាយសិស្សត្រូវហាមឃាត់ជាដាច់ខាត » ។

គ្មានអ្នកណាម្នាក់បដិសេធពីភាពចាំបាច់នៃវិន័យសាលារៀនទេ ។ បើសិនជាថ្នាក់រៀនមួយមានសិស្សពី ៤០ ទៅ ៥០ នាក់ ហើយម្នាក់ៗធ្វើអ្វីៗស្រេចតែនឹងចិត្ត នោះថ្នាក់រៀននឹងគ្មានរបៀបរៀបរយ ជាថ្នាក់រៀនអនាធិបតេយ្យ ។ ក្នុងករណីនេះការបង្រៀនពិតជាគ្មានប្រសិទ្ធភាព ហើយសុំកុំឆ្ងល់ឡើយពីលទ្ធផលសិក្សាដែលត្រូវបានទទួលស្គាល់ថាបរាជ័យទុកជាមុន ។ ដើម្បីសំរេចបាននូវលទ្ធផលល្អក្នុងការសិក្សា គ្រូត្រូវបង្ខំសិស្សអោយគោរពបានវិន័យសាលារៀនផង និង គ្រូត្រូវមានការចាំបាច់ដើម្បីគោរព និងបណ្ដុះបុគ្គលិកលក្ខណៈរបស់កុមារផង ក្នុងនេះការគោរពសិទ្ធិកុមារ ក្នុងឋានៈកុមារជាមនុស្ស ។

« គេផ្សាំងដំរី ប៉ុន្តែគេអប់រំមនុស្ស »

ដើម្បីសំរេចភារកិច្ចទាំងពីរនេះ គ្រូត្រូវយកចិត្តទុកដាក់លើគោលការណ៍ជាសារវន្តទាំងឡាយដូចតទៅនេះ ៖

- ត្រូវអនុវត្តវិន័យសេរី ពោលគឺស្វ័យវិន័យ រឺ ស្វ័យអប់រំ ។ វិន័យពីអតីតកាលត្រូវលុបបំបាត់ ។ វិន័យបច្ចុប្បន្នមិនបង្ខិតបង្ខំអោយកុមារចុះញ៉មដោយកាច់បំបាក់បុគ្គលិកលក្ខណៈទេ ។ ការអប់រំដែលកុមារយល់ថាត្រូវតែគោរពវិន័យបានធ្វើអោយកុមារធ្វើការសំរេចចិត្តមួយ ដោយបានពិចារណាដោយមនោសញ្ចេតនាទទួលខុសត្រូវ ដោយបានដឹងហេតុនិងផល ។

- ច្បាប់មួយដែលគេទទួលស្គាល់ លុះត្រាតែច្បាប់នោះត្រូវបានគេស្គាល់ និងបានយល់ច្បាស់លាស់ ។ គ្រូត្រូវអាន រឺ ធ្វើអោយសិស្សអានដោយពន្យល់នូវមាត្រានិមួយៗ ដើម្បីអោយសិស្សយល់ថា បទបញ្ជាផ្ទៃក្នុងមានប្រយោជន៍ចាំបាច់ ក្នុងការរួមរស់ និងសិក្សាមានប្រសិទ្ធភាពក្នុងសាលារៀន ។ កាលបើគេបានយល់ហើយ គេនឹងចត់ចែងឥរិយាបថរបស់គេទៅតាមនោះ ។ បើសិនជាសិស្សម្នាក់ៗគោរពវិន័យដែលខ្លួនបានយល់ ថ្នាក់រៀនក៏ដូចជាសាលារៀន នឹងមានដំនើរការល្អតាមការគ្រោងទុក គឺជាការអប់រំសេរី ដែលមានមូលដ្ឋានផ្អែកលើការងារដែលបានរៀបចំ ។
- សមធម៌តំរូវអោយបទបញ្ជាផ្ទៃក្នុងនេះ ត្រូវបានអនុវត្តសំរាប់គ្រប់សិស្សានុសិស្សទាំងអស់ដោយគ្មានលើកលែង ។ ប៉ុន្តែបទបញ្ជាផ្ទៃក្នុងមានតែមួយ អត្តចរិតសិស្សប្លែកៗគ្នា ។ ប្រការនេះទាមទារអោយគ្រូ មានការឈ្លាសវៃ ក្នុងការប្រើប្រាស់រង្វាន់ រឺ ទណ្ឌកម្មតាមបែបបទទន់ភ្លន់ និង សំរបសំរួល ។
- ប្រការចុងក្រោយ គ្រូត្រូវតែចងចាំថា ៖
  . បើគ្រូបំពេញមុខងាររបស់ខ្លួនមិនបានត្រឹមត្រូវ ដូចជាមិនបានតែងការបង្រៀន រឺ ក៏មិនគោរពពេលវេលាជាដើម នាំអោយសិស្សគ្មានវិន័យ
  . បើគ្រូបានបំពេញមុខងាររបស់ខ្លួនដោយមានមនសិការវិជ្ជាជីវៈខ្ពស់ និងមានពលីកម្មក្នុងមុខងារ នោះនាំអោយកើតវិន័យជាស្វ័យប្រវត្តិ និង មានប្រសិទ្ធភាព ។
  . « គ្មានទេ សិស្សអាក្រក់នោះ មានតែសិស្សដែលតំរង់មិនទាន់ត្រូវ »
  . « ដើម្បីស៊ុក្រឹតការវិន័យសិស្ស គ្រូត្រូវស៊ុក្រឹតការវិន័យខ្លួនឯង »
  . « ដើម្បីធ្វើអោយសិស្សមានវិន័យ គ្រូត្រូវធ្វើអោយសិស្សរវល់ »
  . « សិស្សភាគច្រើនគ្មានវិន័យ គឺគ្រូទេដែលត្រូវទទួលការចោទប្រកាន់ »

**ដោយ ឃ៉ាច សុត**

---

# ល្បែងល្បងប្រាជ្ញា



សូមកាត់រូបខ្វែងជើងក្អែកនេះ អោយបាន ៤ ចំនែកស្មើៗគ្នា ហើយផ្គុំអោយបានជាការេមួយ មានទំហំស្មើនិងទំហំរូបខ្វែងមុនពេលកាត់ ។

**( ចំលើយនឹងជូននៅលេខក្រោយ )**

# ការរៀបចំអោយសិស្សអង្គុយ

# ( Placement des élèves )

ជាទូទៅ លោកគ្រូ - អ្នកគ្រូ មិនសូវចាប់អារម្មណ៍អំពីបង្គុយរបស់សិស្សទេ ។ សិស្សភាគច្រើនរកកន្លែងអង្គុយដោយខ្លួនឯង ។

តើបង្គុយរបស់សិស្ស មានការពាក់ព័ន្ធនឹងចិត្តគរុកោសល្យដែរទេ ?

ហេតុអ្វី បានជាចាំបាច់ត្រូវយល់ដឹងពីបង្គុយរបស់សិស្ស ?

## មុខងារនៃអាយតនៈ ( ប្រដាប់វិញ្ញាណ )

អាយតនៈរបស់មនុស្សយើង មានប្រាំគឺ ភ្នែក ត្រចៀក កាយ ( ពិសេស គឺបាតដៃ និងម្រាមដៃ ) មាត់ និងច្រមុះ ។ អាយតនៈនីមួយៗមានមុខងារផ្ទាល់របស់វា ហើយមានសារៈសំខាន់ដូចគ្នា ត្រូវបំពេញគ្នាទៅវិញទៅមក ។

- **ភ្នែក** ជាសរីរាង្គនៃចក្ខុវិញ្ញាណ មានតួនាទីសំរាប់ទាក់ទងនឹងលោកទាំងមូល ។ យើងស្គាល់ពិភពលោកតាមរយះភ្នែក ។
- **ត្រចៀក** ជាសរីរាង្គនៃសោតវិញ្ញាណ មានតួនាទីសំរាប់ស្តាប់ភាសា និងស្នូរសំលេងគ្រប់យ៉ាង ។
- **ដៃ** ជាសរីរាង្គនៃកាយវិញ្ញាណ មានតួនាទីសំរាប់ចាប់កាន់ ដឹងក្តៅត្រជាក់ រឹង ទន់ ហើយអនុវត្តរាល់សកម្មភាពដែលមនុស្សត្រូវបង្កបង្កើត ។
- **មាត់** ជាសរីរាង្គនៃជីវ្ហាវិញ្ញាណ មានតួនាទីសំរាប់និយាយឆ្លើយឆ្លង បញ្ចូលអាហារសំរាប់ទ្រទ្រង់រាងកាយ និង ស្គាល់រសជាតិគ្រប់យ៉ាង ។
- **ច្រមុះ** ជាសរីរាង្គនៃឃានវិញ្ញាណ មានតួនាទីសំរាប់បញ្ចូលអុកស៊ីសែន ទ្រទ្រង់ជីវិត និងបញ្ចេញឧស្ម័នពុល ហើយស្គាល់ក្លិនគ្រប់ប្រភេទ ។

លំនឹករបស់មនុស្ស ពិសេសលំនឹករបស់សិស្ស អាស្រ័យដោយអាយតនៈទាំងអស់ ។ សិស្សអាចចងចាំដោយឃើញ ( លំនឹកភ្នែក ) ដោយឮការពោលពាក្យ ( លំនឹកត្រចៀក ) ដោយបានពោលថា ( លំនឹកសំដី ) ដោយភ្លក្ស និងហិតក្លិន ។ អាស្រ័យហេតុនេះហើយ ទើបគរុកោសល្យតំរូវអោយអ្នកបង្រៀន មានសំភារឧបទេសជាជំនួយដល់ស្មាមតំនូស ។ ការថាតាមគ្នា រឺ ថាឡើងវិញជារឿយៗ ជាព្រលឹងនៃការបង្រៀន ( La répétition est l' âme de l'enseignement ) ។

តាមរយៈនេះគេឃើញថា ការបង្រៀនចោទទៅលើអាយតនៈបីខ្លាំងជាងគេ គឺភ្នែក ត្រចៀក និង ដៃ ។

អ្នកបង្រៀនគប្បីពង្រឹងចំនេះដឹងសិស្ស តាមរយៈអាយតនៈទាំងបីនេះ ។ អ្នកខ្លះចងចាំ ដោយគ្រាន់តែបានឃើញ អ្នកខ្លះចងចាំដោយគ្រាន់តែបានឮ ដូចករណីមនុស្សខ្វាក់ជាដើម ។ ឯអ្នកខ្លះទៀត ទាល់តែទន្ទេញបញ្ចេញសំលេងពីមាត់ខ្លួនឯង បញ្ចូលទៅត្រចៀកខ្លួនឯងវិញទើបចងចាំបាន ។ មានសិស្សខ្លះ ចងចាំដោយសារចលនាម្រាមដៃសរសេរខ្មៀកចុះខ្មៀកឡើង ។ នៅពេលដែលខ្មៀកមិនបានដូចសព្វមួយដង គេដឹងភ្លាមថា ខុសអក្ខរាវិរុទ្ធហើយ ។

កាលពីដើម អ្នកស្រុកនាំកូនទៅអោយ « នៅក្ដី » គឺនាំទៅប្រគេនលោកគ្រូចៅអធិការ សុំពឹងពាក់អោយលោកជួយប្រោសសត្វ បង្រៀនអក្សរ គណិតវិទ្យា អប់រំចរិយាមារយាទ អោយស្គាល់បាបបុណ្យ គុណ ទោស អោយចេះធ្វើវត្តប្រណិប័តន៍ ។ ល ។ ដោយពិតទូលលោកថា « សូមព្រះតេជគុណ វាយដំពត់រោលតាមសព្វព្រះទ័យចុះ សុំកុំអោយតែខ្វាក់ភ្នែក និង បាក់ឆ្អឹង » ។ ឆ្លុះបញ្ចាំងតាមទំលាប់ខាងលើនេះ យើងឃើញថា អាណាព្យាបាល ក៏ទុកភ្នែកជាសរីរាង្គសំខាន់ជាងគេដែរ ។

# ពិសោធន៍ទស្សនវិស័យ រឺ កំលាំងភ្នែកមើលឃើញ

## គេអាចធ្វើតេស្ដភ្នែក ចាប់ពីកុមារអាយុ ៣ ឆ្នាំឡើងទៅ ។

## សំភារៈសំរាប់ពិសោធន៍

១ - រូបសញ្ញាសំរាប់កាន់យក
តាមរូបមួយណាក៏បាន


រូបទី ១


រូបទី ២

២ - ធ្វើផ្ទាំងសញ្ញាពណ៌ខ្មៅ បិទលើផ្ទៃពណ៌ស ។

| ខ្ទង់ | ផ្ទាំងសញ្ញា | កំពស់សញ្ញា |
|---|---|---|
| ទី ៥ |  | ៦ ស.ម |
| ទី ៤ |  | ៤ ស.ម កន្លះ |
| ទី ៣ |  | ៣ ស.ម |
| ទី ២ |  | ១ ស.ម កន្លះ |
| ទី ១ |  | ៧ ស.ម |

# របៀបធ្វើតេស្ត

១- ព្យួរផ្ទាំងសញ្ញានៅជញ្ជាំង រឺ នៅក្តារខៀន ។

២- អោយសិស្សឈរឃ្លាតពីផ្ទាំងសញ្ញាចំងាយ ៦ ម ដៃកាន់រូបសញ្ញា ។

៣- លោកគ្រូចង្អុលរូបសញ្ញាណាមួយនៅខ្ទង់ទី ១ ។

៤- អោយសិស្សយកបាតដៃខ្ទប់ភ្នែកម្ខាង ហើយលើករូបសញ្ញា ដោយដាក់អោយរូបសញ្ញានោះមានលំនាំដូចរូបសញ្ញាទៅលើផ្ទាំង ។ ធ្វើភ្នែកម្ខាង រួចហើយប្តូរទៅធ្វើភ្នែកម្ខាងទៀត ។

៥- បើសិស្សធ្វើបានដូចរូបសញ្ញានៅខ្ទង់ទី១ បានន័យថា ទស្សនវិស័យរបស់វាល្អណាស់ ។ ជួនកាលភ្នែកឆ្វេង និងភ្នែកស្តាំ មើលឃើញខុសគ្នា បានសេចក្តីថា ភ្នែកមួយមានកំលាំងឃើញល្អជាងភ្នែកម្ខាងទៀត ។

៦- បើសិស្សធ្វើបានល្អដូចរូបសញ្ញានៅខ្ទង់ទី១ ដោយភ្នែកទាំងសងខាង គារធ្វើតេស្តត្រូវបញ្ចប់ ។ មិនចាំបាច់ធ្វើនៅខ្ទង់ទី២ ទៀតទេ ពីព្រោះទស្សនវិស័យរបស់វា ល្អត្រឹមត្រូវហើយ ។

៧- បើភ្នែកណាមួយមើលមិនឃើញ ហើយដាក់សញ្ញាមិនដូច នោះត្រូវធ្វើបន្តទៅខ្ទង់ឯទៀតៗ ។

៨- ទស្សនវិស័យនៅខ្ទង់ទី១ ល្អណាស់ ខ្ទង់ទី២ ល្អ ខ្ទង់ទី៣ បង្គួរ ខ្ទង់ទី៤ អន់ ខ្ទង់ទី៥ ខ្សោយ ។

# តារាងកត់ត្រាលទ្ធផលនៃការធ្វើតេស្ត

| ភ្នែក | ល្អណាស់ | ល្អ | បង្គួរ | អន់ | ខ្សោយ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ឆ្វេង | √ | | | | | |
| ស្តាំ | | | √ | | | |

ឧបមាថា ភ្នែកឆ្វេងល្អណាស់ ត្រូវគៀសត្រង់ខ្ទង់ល្អណាស់ បើភ្នែកស្តាំបង្គួរ ត្រូវគៀសត្រង់ខ្ទង់បង្គួរ ។ ល ។ ធ្វើដូច្នេះគ្រប់សិស្សទាំងអស់ ។ អាស្រ័យហេតុនោះ សិស្សម្នាក់ៗ ត្រូវមានសាលាកប័ត្រពតិមានដូចជា ៖

- ឈ្មោះ ................................ ភេទ ................ អាយុ ................................
- ឈ្មោះឪពុក ................................ ឈ្មោះម្តាយ ........................ មុខរបរ ..............
- ទីលំនៅ រឺ អាស័យដ្ឋានពិត ................................................................

ភ្ជាប់ដោយតារាងកត់ត្រាលទ្ធផលនៃការធ្វើតេស្ត ។

# ការរៀបចំអោយសិស្សអង្គុយ

១- សិស្សតូចអង្គុយជួរមុខ ហើយសិស្សធំអង្គុយជួរក្រោយ ដើម្បីកុំអោយបាំងក្បាលសិស្សតូច ។

២- បើសិស្សធំអន់ភ្នែក ត្រូវអោយអង្គុយជួរមុខដែរ ប៉ុន្តែនៅខាង ដោយអោយភ្នែកភ្លឺនៅក្នុង បាន

សេចក្ដីថា បើអន់ភ្នែកស្ដាំ ត្រូវអង្គុយនៅខាងស្ដាំ ដើម្បីអោយភ្នែកឆ្វេងមើលឃើញក្ដារខៀនច្បាស់ ។ បើអន់ភ្នែកឆ្វេង ត្រូវអង្គុយនៅឆ្វេង ដើម្បីអោយភ្នែកស្ដាំនៅក្នុង ។

## វិធីការពារភ្នែក

១- កុំយកដៃកខ្វក់ទៅពាល់ភ្នែក ។ អ្នកបង្រៀនគប្បីត្រួតពិនិត្យក្នុងត្រចៀក និងក្រចកដៃសិស្ស នៅពេលតំរង់ជួរចូលថ្នាក់ ។ នៅក្នុងថ្នាក់ ត្រូវមានសំភារៈអនាម័យ ដូចជា ធុងទឹក កន្សែង សាប៊ូ កន្ត្រៃកាត់ក្រចក កញ្ចក់ . ក្រាស ។ល ។

២- កុំអានសៀវភៅកណ្ដាលថ្ងៃ ពីព្រោះថាំងថ្ងៃ ធ្វើអោយហៀរទឹកភ្នែក ។

៣- សរសេរ រឺ ដាក់សៀវភៅអាន ចំងាយ ៣០ ស.ម ពីភ្នែក លើកលែងតែភ្នែកខ្សោយ ។

៤- កុំកាន់របស់ស្រួច មានកូនកាំបិត និងកន្ត្រៃជាដើមហើយរត់ ។ នៅពេលផិតប់ជើងដួល អាចបុកភ្នែក បណ្ដាលអោយពិការ ។

## គរុកោសល្យ

១- បង្ហាញតួអក្សរនៅក្ដារខៀន ត្រូវសរសេរអោយធំ ហើយច្បាស់ ។

២- រូបភាព និង សំភារៈ បើបានជីវិតតែល្អ ។ បើរូបភាព រឺ សំភារៈតូច គប្បីបង្ហាញតាមជួរតុនីមួយៗ ព្រមទាំងបញ្ជាក់ចំនុចដែលចង់អោយសិស្សសង្កេត ចៀសវាងបង្ហាញទទេៗ ដោយគ្មានណែនាំ ពីព្រោះសិស្សមិនទាន់ចេះសង្កេតចំនុចដោយខ្លួនឯងទេ ។ វាសង្កេតតែចំនុចរួមប៉ុណ្ណោះ ។ ម្យ៉ាងទៀត រូបភាពឃើញមិនច្បាស់ អាចច្រឡំនឹងរូបភាពផងទៃ ។ ឧទាហរណ៍ : រូបសត្វក្រាបនិងរូបសត្វលលក ។ សញ្ញា = និងសញ្ញា ≠ ។ សិស្សអាចគូសយ៉ាងនេះ × ។ សំពប់មនុស្សធំផងដែរ ស្លឹកត្នោតមួយធាង ផ្ទះផ្ដែកនៅតល់ វាក្រូវពន្លឺព្រះចន្ទ្រ អាចច្រឡំនឹងខ្មោចលងទទូលសំពត់ស ។ មើលពីចំងាយ បឹងរាងបួនជ្រុងហាក់ដូចជារាងមូល (Erreur optique) ។

៣- ពាក្យពេចន៍ដែលត្រូវបញ្ជាក់ រឺ ចំនុចពិសេសណាមួយដែលត្រូវបញ្ជាក់ គប្បីយកដីសពណ៌គូសពីក្រោម ។

## ការធ្វើតេស្តត្រចៀកសិស្ស

ខ្សឹបដាក់ត្រចៀកទាំងសងខាង ហើយចោទសំនួរអោយឆ្លើយ ។

## តារាងកត់ត្រាលទ្ធផលនៃការធ្វើតេស្ត

| ត្រចៀក | ល្អណាស់ | បង្គួរ | អន់ | ថ្លង់ | ផ្សេងៗ |
|---|---|---|---|---|---|
| ឆ្វេង | √ | | | | |
| ស្ដាំ | | | √ | | |

# ការរៀបចំអោយសិស្សអង្គុយ

រៀបចំអោយអង្គុយដូចលក្ខណៈកែ្នកដែរ ធ្វើយ៉ាងណាអោយត្រចៀកច្បាស់នៅក្នុង ។

## វិធីការពារត្រចៀក

១- កុំយករបស់រឹង រឺ ស្រួចទៅត្បារ រឺ រុកលេងក្នុងរន្ធត្រចៀក ។

២- កុំអោយទឹកចូលត្រចៀក នាំអោយកើតអំបោអំបែក ។ ក្រោយពេលងូតទឹក រឺ ពេលផ្លូតទឹក គប្បីយកសំឡីត្បារអោយស្អាត ។

៣- កុំទះកំផ្លៀង ពិសេសគឺទះទាំងសងខាង ។

## ល្បែងអប់រំ

១- អោយស្ងៀមស្ងាធិស្តាប់សូរ (សំរឹប) នៅជុំវិញខ្លួន តើអ្វីខ្លះ ?

២- យកដៃខ្ទប់ត្រចៀកទាំងពីរ ហើយប្រឹងស្តាប់សិស្សឯទៀតនិទានរឿងនៅជិតនោះ តើឮអ្វីខ្លះ ?

៣- ពិនិត្យសង្កេតបប្ដូរមាត់អ្នកនិយាយច្បាស់ ។

៤- លេងព័ទ្ធវង់អោយអ្នកត្រចៀកអន់នៅកណ្តាល ហើយយកកូនកន្ទ្បេងចងមុខ ។ អោយអ្នកនៅជុំវិញទះដៃ រួចប្តូរទីតាំង រឺ ប្តូរគ្នាទះដៃ ។

៥- អោយអ្នកនៅកណ្តាលវង់ចង្អុរសំដៅស្នូរ ។

## គរុកោសល្យ

១- គ្រូនិយាយមួយៗ ហើយច្បាស់ ។

២- ហៅសិស្សអន់ត្រចៀក អោយថាតាមចំលើយល្អរបស់គេជាញឹកញាប់

៣- ចោទសួរសិស្សអន់ត្រចៀកអោយបានញឹកញយ

៤- អនុញ្ញាតអោយសិស្សត្រចៀកល្អ ជួយប្រាប់បន្ថែមនូវការពន្យល់របស់គ្រូ លើកលែងតែសរសេរតាមអាន ចំណោទ រឺ លំហាត់ផ្សេងៗ

៥- កុំស្រែកសង្ឃក ពីព្រោះសំរែកពិបាកញែករលកសំលេងណាស់ ។

## ការអប់រំកាយវិញ្ញាណ

១- ណែនាំអោយលើកដៃឆ្វេង ដៃស្តាំ លើកឡើងទៅមុខ ទៅក្រោយ ទៅឆ្វេង ទៅស្តាំ...

២- ណែនាំអោយកាន់ដីស ខ្មៅដៃ ប៊ិច ។ល ។

៣- ណែនាំអោយចេះចិតខ្មៅដៃ

៤- ណែនាំអោយចេះគូររូប លញ់ដីឥដ្ឋ កាត់ក្រដាស វែង ត្បាញ រហូតដល់ខ្មៅខ្លួង ។

## ការយល់ដឹងពី ពីញ៉ៀ (Pignet)

១- អោយសិស្សដកដង្ហើមចូល យកម៉ែតសំពត់វាស់បរិមាត្រទ្រូងរបស់វាត្រង់ដោះ ហើយកត់ត្រាជាសង់ទីម៉ែត ។

២- អោយដកដង្ហើមចេញ ហើយវាស់ម្ដងទៀត ។

៣- ផលបូកដង្ហើមចូល និង ដង្ហើមចេញចែកជាពីរ ទុកជាខ្នាតទ្រូង ។

៤- ថ្លឹងទំងន់ កត់ត្រាជាគីឡូក្រាម ( ដោះស្បែកជើងចេញ )

៥- វាស់កំពស់ កត់ត្រាជាសង់ទីម៉ែត ។ ឈរផ្អប់ទឹងជញ្ជាំងអោយជង្ងន់ រត់ត្រង់ក្បាលមិនអោន មិនងើប ។ វាស់ពីកន្ទួលក្បាលមកដល់ដី ។

៦- ខ្នាតទ្រូង និងទំងន់បូកបញ្ចូលគ្នា យកទៅសងរង្វាស់កំពស់ ឃើញពីញ៉ៀ ។

*ឧទាហរណ៍* ៖

- ខ្នាតទ្រូង B = 65 ស.ម
- ទំងន់ C = 35 គ.ក
- កំពស់ D = 140 ស.ម
- ពីញ៉ៀ A = D - ( B + C ) = 140 - 100 = 40 ។

## លទ្ធផល

- បើ A តិចជាង 39 សិស្សនោះមានសុខភាពល្អ ។

- បើ A ចាប់ពី 39 ឡើងទៅឃើញថា សិស្សនោះមានរាងចោងដោង ប៉ុន្តែប្រដាប់ដង្ហើមខ្សោយ ហើយទំងន់តិច ប្រៀបដូចរថយន្តមានទ្រុងធំ ប្រឹងផ្ទុកច្រើន ប៉ុន្តែ ម៉ាស៊ីនអន់ អូសទាញទាំងត្រដាបត្រដួស បណ្ដាលអោយយូរៗទៅខូចទាំងម៉ាស៊ីនថែមទៀត ។ យ៉ាងណាមិញ ពីញ៉ៀច្រើន ក៏យ៉ាងនោះដែរ ។

ដូចនេះ ត្រូវខិតខំធ្វើតាយសិក្សា និង បំប៉នរបបអាហារ ។

សង្ខេបមក ការយល់ដឹង និង អនុវត្តន៍តាមប្រការខាងលើនេះ សមស្របតាមចិត្តសាស្ត្រផង តាមគរុកោសល្យផង ប្រសើរជាជាង « សំពង » សិស្សដោយគ្មានដឹងដើមទង ។

« ព្រលឹងសុខសប្បាយ ស្ថិតនៅក្នុងរាងកាយសុខសប្បាយ L' âme saine dans un corps sain >> ។

**ដោយលោក ឈឹម សំផុន**
**គ្រូបង្រៀនចូលនិវត្តន៍នៅខេត្តកំពត**

# ឧបទ្ទេស - ការបង្រៀនចំនួន ៧

## លំនាំមេរៀន

**I- បញ្ជាក់មេរៀនពីថ្ងៃមុន :** គឺបញ្ជាក់ថា សិស្សបានស្គាល់ចំនួន ៦ ហើយរឺនៅ ចេះបូកដកក្នុងរង្វង់ចំនួន ៦ រឺទេ ។ ដើម្បីបញ្ជាក់គ្រូអោយសិស្សផ្គុំ និង បំបែកចំនួន ៦ នៅលើតុ ដោយសំភារៈផ្ទាល់ខ្លួន ។

| | |
|---|---|
| ៥ + ១ = ៦ | ៦ = ៣ + ៣ |
| ២ + ៤ = ៦ | ៦ = ៤ + ២ |
| ១ + ២ + ៣ = ៦ | ៦ = ៥ + ១ |

- អោយសិស្សសរសេរនៅលើក្តារឆ្នួន លេខបូកក្នុងរង្វង់ ៦ តាមបញ្ជាគ្រូ ។ ឧទាហរណ៍ : ៤ + ២ , ១ + ២ + ៣

**II- មេរៀនប្រចាំថ្ងៃ :** មេរៀនចំនួន ៧

**១- ដំនាក់កាលរូបី :** គឺជាដំនាក់កាលផ្គុំចំនួនរូបី ដោយសំភារៈដូចជា ចង្កឹះ ខ្មៅដៃ ស្លឹកឈើ រឺគំរបដប ។
គ្រូអាចប្រើវិធីបីយ៉ាង :

ក- សិស្សមានចង្កឹះ ៦ ដើមនៅដៃ ហើយរាប់ម្តងមួយៗ ។ គ្រូអោយសិស្សយកចង្កឹះមួយ ( ១ ) ដើមទៀត មកបង្ហាញសិស្ស ហើយផ្គុំបញ្ចូលគ្នា ។ សិស្សលើកបង្ហាញចង្កឹះផ្គុំនោះ ហើយគ្រូសួរទៅសិស្សថា តើនៅនឹងដៃក្មួយៗមានចង្កឹះចំនួនប៉ុន្មាន ? បើសិស្សឆ្លើយមិនបានទេ គ្រូត្រូវបំផុសគំនិត ដូចជាថា ៥ + ១ ត្រូវជាប៉ុន្មាន ? ត្រូវជា ៦ ។ ចុះ ៥ + ២ ត្រូវជា ៧ ។

ខ- គ្រូអោយសិស្សយកស្លឹកឈើ ៦ សន្លឹក ដាក់នៅលើតុ ហើយអោយយកមួយ (១) សន្លឹកទៀត មកដាក់បញ្ចូលគ្នា ។ តើនៅមុខសិស្សម្នាក់ៗ មានស្លឹកឈើប៉ុន្មាន ?

គ- គ្រូអាចរៀបសិស្សជាក្រុមក៏បាន ។ ក្រុមនីមួយៗយកគំរបដបចំនួនឯមកដាក់លើតុ ហើយអោយរាប់បញ្ជាក់ចំនួន ។ គ្រូអោយយកគំរបដបមួយ (១) ទៀត មកដាក់បញ្ចូលគ្នា ។ ក្រុមនីមួយៗ រាប់គំរបដបឡើងវិញ ។ គ្រូសរសេរចំនួន ៧ នៅក្តារខៀន ដោយបង្ហាញពីរបៀបសរសេរ ។ គ្រូអានប្រាំ ពីរ ( មិនមែនប្រាំពិលទេ ) អោយបានច្បាស់ ។ គ្រូអោយសិស្ស ២ រឺ ៣ នាក់ឡើងសរសេរលេខ ៧ នៅក្តារខៀន ។ ជាមួយនេះ អោយសិស្សឯទៀតសរសេរនៅលើក្តារឆ្នួនរៀងៗខ្លួន ។

* *ដំនាក់កាលពាក់កណ្តាលរូបី :* គ្រូអោយសិស្សអនុវត្តដូចខាងលើ ដោយយកសំភារៈផ្សេងៗ ដូចជា រូបសត្វ ដើម្បីតាងចំនួន ៧ ។

**២- ដំនាក់កាលអរូបី**

ក- ពាក់កណ្តាលអរូបី គឺជាពេលឆ្លងមួយដ៏លំបាក :

**វិធីទី១ :** គ្រូដាក់រូបកូនមាន់ ៦ ភ្ជាប់ទៅនឹងផ្ទាំងសំពត់ រឺគូររូបត្រីនៅក្តារខៀន ។ រួចរើសរូបកូនមាន់ រឺត្រី ១ ទៀត ទៅបញ្ចូលក្នុងក្រុមឯមុន ។ អោយសិស្សរាប់ចំនួន៧ ។ គ្រូសរសេរលេខ ៧ ក្រោមរូបកូនមាន់ ៧ ។

**វិធីទី២ :** លោកគ្រូមានកូនមាន់ ៧ នៅលើផ្ទាំងសំពត់រួចហើយ ។ គ្រូដាក់រូបកូនមាន់ ៧ មួយក្រុមទៀតស្បែរគ្នា ហើយភ្ជាប់ក្រុមទាំងពីរនេះដោយសញ្ញា = ( ស្មើគ្នា ) គ្រូរាប់កូនមាន់ទាំងសងខាង ហើយឃើញថា រូបកូនមាន់មានចំនួនស្មើគ្នា ។ នេះគឺចង់អោយសិស្សយល់ពីសញ្ញា « = » ។ រួចហើយ គ្រូលុបកញ្ចុំរូបកូនមាន់ខាងស្តាំ ហើយរាប់កញ្ចុំកូនមាន់នៅខាងឆ្វេងឡើងវិញ ។ នៅពេលជាមួយនេះ គ្រូសរសេរចំនួន ៧ នៅកន្លែងកញ្ចុំកូនមាន់ ៧ ដែលត្រូវបានលុប ហើយអានថា រូបកូនមាន់ ៧ នេះស្មើនឹង ( = ) ៧ ដែលជាលេខតាង ។

ខ- ដំនាក់កាលអរូបី គឺជាការបង្ហាញលេខ៧ ដែលជានិមិត្តរូបនៃចំនួន ៧ និងការសរសេរទំនាក់ទំនងអរូបី ៖ ៦ + ១ = ៧ ចាប់ពីពេលនេះ គ្រូ និង សិស្សប្រើតែចំនួនថ្មី ៧ ។

សូមលោកគ្រូ - អ្នកគ្រូ ធ្វើតេស្តពង្រឹងចំនេះដឹង និងលំហាត់មាត់ទទេ នៅលើក្តារឆ្នួនដោយខ្លួនឯង ។

**បណ្តាំផ្ញើ :** ជាទីបញ្ចប់ ខ្ញុំសូមសិក្ខាបទធារី ថ្នាក់ទី១ បង្រៀនពីចំនួន ១ ដល់ចំនួន ២០ ដោយធ្វើដំនើរសន្សឹមៗឈានមួយៗ ។ ការផ្គុំ និងបំបែកចំនួនមានសារៈសំខាន់បំផុត ។ វាជាគ្រឹះមូលដ្ឋាននៃការបង្រៀនពុទ្ធនោបឋមសិក្សា ។ មេរៀននេះ គួរបង្រៀនក្នុង ៣ រឺ ៤ ពេល ។

**កំនត់ចំនាំ :** លំនែនាំមេរៀននេះ អនុវត្តបានទៅលើការបង្រៀនពីចំនួន ១ ដល់ ៩ ។ បើលោកគ្រូ - អ្នកគ្រូ មានវិធីបង្រៀនប្លែកៗពីនេះ សូមសរសេរមក គណៈកម្មាធិការនាយក ស.ប.ស.ខ ដើម្បីផ្សព្វផ្សាយ ។

**ដោយ យ៉ង់ ធី** ✍

# ដំណឹងមរណភាព

គណៈកម្មាធិការនាយកនៃ ស.ប.ស.ខ សូមជូនពត៌មានថា : ក្នុងរយៈពេលមួយឆ្នាំ ពីរខែ ( ចាប់ពីខែ មករា ១៩៩៥ មកដល់ដំណាច់ខែ កុម្ភៈ ១៩៩៦ ) សមាជិក-សមាជិកាយើងបានទទួលអនិច្ចកម្មទាំងអស់ចំនួន **៣០២** នាក់ ។ រីឯគូស្រករ ( ប្តី រឺ ប្រពន្ធ ) ចំនួន : **២៥១ នាក់** ដូចតារាងខាងក្រោម ៖

| ល.រ | ឈ្មោះខេត្ត | ចំនួនសព សមាជិក | ល.រ | ឈ្មោះខេត្ត | ចំនួនសព សមាជិក | ផ្សេងៗ |
|---|---|---|---|---|---|---|
| ០១ | មន្ទីរក្រសួងអប់រំ យុវជន និង កីឡា + អង្គភាពចំណុះ | ១០ នាក់ | ១១ | ខេត្ត ស្វាយរៀង | ១៣ នាក់ | |
| ០២ | ខេត្ត តាកែវ | ២២ - | ១២ | - ព្រៃវែង | ៣៧ - | |
| ០៣ | - កំពង់ធំ | ១៤ - | ១៣ | - បាត់ដំបង | ២០ - | |
| ០៤ | - សៀមរាប | ១៩ - | ១៤ | - កំពង់ឆ្នាំង | ១០ - | |
| ០៥ | - កណ្តាល | ៣៥ - | ១៥ | - កំពង់ស្ពឺ | ១៤ - | |
| ០៦ | - កំពង់ចាម | ៣៩ - | ១៦ | - រាជធានីភ្នំពេញ | ០៧ - | |
| ០៧ | - បន្ទាយមានជ័យ | ១៥ - | ១៧ | សកលវិទ្យាភ្នំ.ព | ០២ - | |
| ០៨ | - កំពត | ១៦ - | ១៨ | ខេត្ត ពោធិ៍សាត់ | ០៤ - | |
| ០៩ | - ក្រចេះ | ១១ - | ២០ | បច្ចេកទេស - ឧស្សាហកម្ម | ០១ - | |
| ១០ | - ក្រុងព្រះសីហនុ | ០៤ - | ១៩ | - ព្រះវិហារ | ០៩ - | |
| | | សរុប : | .......... | ..................= | ៣០២ នាក់ | |

| ល.រ | ឈ្មោះ ខេត្ត | ចំនួនសពគ្រួសារ ( ប្តី ឬ ប្រពន្ធ ) | ល.រ | ឈ្មោះ ខេត្ត | ចំនួនសពគ្រួសារ ( ប្តី ឬ ប្រពន្ធ ) | ផ្សេងៗ |
|---|---|---|---|---|---|---|
| ០១ | ម.ន្ទ.ក្រ.អ.រ.យ.ក+ចំ.ក្រ.ស | ០៥ នាក់ | ១១ | ខេត្ត ស្វាយរៀង | ០៥ នាក់ | |
| ០២ | ខេត្ត តាកែវ | ១៥ - | ១២ | - ព្រៃវែង | ៣៥ - | |
| ០៣ | - កំពង់ធំ | ២៥ - | ១៣ | - បាត់ដំបង | ១៣ - | |
| ០៤ | - សៀមរាប | ១៤ - | ០៤ | - ព្រះវិហារ | ០៣ - | |
| ០៥ | - កណ្តាល | ២៦ - | ០៥ | - កំពង់ឆ្នាំង | ០៧ - | |
| ០៦ | - កំពង់ចាម | ៣៧ - | ០៦ | - កំពង់ស្ពឺ | ១៥ - | |
| ០៧ | - បន្ទាយមានជ័យ | ០៧ - | ១៧ | - រាជធានីភ្នំពេញ | ១៧ - | |
| ០៨ | - កំពត | ១០ - | ១៨ | - ពោធិសាត់ | ០៤ - | |
| ០៩ | - ក្រចេះ | ០៤ - | ១៩ | - ស្ទឹងត្រែង | ០៣ - | |
| ១០ | - ក្រុងព្រះសីហនុ | ០៥ - | ២០ | - កោះកុង | ០១ - | |
| | | សរុប : | ........................................ | = | ២៥១ នាក់ | |

ការអប់រំ គឺ ជាភារកិច្ចរបស់ យើងទាំងអស់គ្នា

រោងពុម្ព ក្រសួងអប់រំ